# ល្បើកអង្គរវត្ត

## និពន្ធដោយ ប៉ាង ខាត់

## (១៥៤២ស័ក, ព.ស.២១៦៣, គ.ស.១៦២០)

(ចម្លងជាអក្សរ និងអក្ខរាវិរុទ្ធខ្មែរទំនើបដោយ ហម ឆាយលី តាមឯកសាររបស់អែម៉ូនីញេ អេត្យែនន៍ ដែលចម្លងដោយលោក សុន ឡេប បោះពុម្ពនៅក្រុងព្រៃនគរ ឆ្នាំ១៨៧៨) ។

**កំណត់** : ការចម្លងជាថ្មី និងអក្ខរាវិរុទ្ធនេះ ខ្ញុំផ្ទៀងផ្ទាត់តាមវចនានុក្រមរបស់ពុទ្ធសាសនបណ្ឌិត្យ, ក្បាលទី១ បោះពុម្ព ឆ្នាំ១៩៦៧ និង ក្បាលទី២ បោះពុម្ព ឆ្នាំ១៩៦៨ ។

១. សាស័ព្ទសេដ្ឋោ ឯកបញ្ចោ សសោត្តមំ ឆ្នាំវកនក្សត្រ
វិវឡនំ សាធុការំ តិលកាលំ ។

២. ខ្ញុំអង្គអំបូរ ពូជពង្សត្រកូល ជាតិវង្សា នាមនៃអ្នកប៉ាង
តាតសាងសាស្ត្រា ល្បើកអង្គរជា ច្បាប់ទៅមុខហោង ។

៣. មានចិត្រសទ្ធា អាចចារសាស្ត្រា ដោយដានគន្លង គាថាបាលី
ពិតពីព្រេងហោង មែនដូច្នេះហោង ពុំឃ្លាតឡើយណា ។

៤. អង្គអញខ្ញុំសូម សំណាងសំណូម បានបរិបូណ៌ប្រា កដដូចខ្ញុំគិត
ក្នុងចិត្រប្រាថ្នា កុំឱ្យមានឃ្លា ឃ្លាតដល់តិចឡើយ ។

### បទព្រហ្មគិត

៥. តែងជាបទព្រហ្មគិត លើកដោយគិតតាមទំនង ដំណើរពីមុនហោង
អ្នកប្រាជ្ញលោកលើកមកស្រាប់ ។

៦. ខ្ញុំនៅសូមពណ្ណរាយ ប្រកបកាយជាតិចំណាប់ ចំណងចងជាស័ព្ទ
ជាត្រកាលពេកក្ដាត់ណា ។

៧. អង្គអញសូមកំណើត កបកាលកើតៗនៅនា ស្ថានសួគ៌ត្រៃត្រឹង្សា

ពិតពុំឃ្លាឃ្លាតឡើយហោង ។

៨. ខ្ញុំសូមកំណើតគាប់ ជាសម្រាប់ព្រះអង្គហោង ព្រះសីអារ្យកន្ទង
លែងទេព្ភានៅស្ងត៌នាយ ។

៩. កាលព្រះចាកច្យុត ស្រៀបស្រាប់ស្រុតសោះសព្វសាយ ចាប់ព្រះបដិសន្ធិឆ្ងាយ
បរិបូណ៌បានត្រាសហើយហោង ។

១០. ខ្ញុំសូមកុំឱ្យឃ្លាត យោនយកជាតិថ្ងៃមួយផង ព្រះអង្គនោះឯងហោង
សូមបានដួចប៉ងប្រាថ្នា ។

១១. ខ្ញុំសូមបានរៀនធម៌ ចប់អស់អាចិត្រៃភេទផង សូមចិត្រល្អកន្ទង
ជាសំឡាញ់និងញាតិផៅ ។

១២. ខ្ញុំសូមមានសំឡឹង សូរស័ព្ទផ្សឹងក្រាំងក្រនី រម្ងាប់ចិត្រនិត្យនៅ
អស់អ្នកផងទប់ពុំបាន ។

១៣. ខ្ញុំសូមមានប្រាជ្ញា កាត់សទ្ធាពន់ប្រមាណ ខ្ញុំសូមបានឱ្យទាន
អស់ទាំងសូមយាចកផង ។

១៤. សំណូមនេះឯណា ខ្ញុំប្រាថ្នាស្រាប់ហើយហោង សូមបានដួចបំណង
នៃអញខ្ញុំសូមប្រាថ្នា ។

១៥. ត្រៃភពសារសុចរិត វរវិរិគហប្ញទ័យា ឱនអង្គអរសទ្ធា
គ្រួញក្រាបក្រោមព្រះលាយលក្សណ៍។

១៦. ទោះទាំងផ្ទលីថ្មើង លុតលើកឡើងស្មោះដោមដាក់ សិរសាដាក់ជៀងជាក់
ថ្វាយវន្ទានិនលំអុត ។

១៧. ស្មោះស្មានពីចិត្រចង់ បង្គំត្រង់ព្រះសម្ពុទ្ធ ស្តែងស្តេចជាមកុដ
ត្រៃភពភាផងទាំងឡាយ ។

១៨. ព្រះអង្គគីភេត្រា មាលមាសមារតធំរៀងរាយ រស្មីភ្លឺព្រោងព្រាយ
ចិញ្ចែងចាំងទាំងសាកល ។

១៩. ផ្ទលផ្ទុកសព្វសត្វផង នានាំឆ្លងដោមដាក់ដល់ និព្វានស្ថានមង្គល
ប្រាសនិរាសជាតិជរា ។



២០. នោះអញខ្ញុំសង្វាត ឧស្សាហ៍ឃ្នាតខ្មីចិន្តា ចាប់ចងជាកាព្យ
សូត្រសរសើរព្រះបារមី ។

២១. ស្តេចអាចផ្ចាញមារា នោះពុះពារមារយាយី បាក់បបបង់ទិដ្ឋី
ទ្រើសលែងលុះដោយចេស្តា ។

២២. យើងខ្ញុំស្រណោះសល់ ដ្បិតពុំយល់ព្រះធម្មា យល់តែព្រះរូបា
ស្ថិតលើអាសនៈព្រះអង្គ ។

២៣. ទើបខ្ញុំត្រេកសទ្ធា ឱនសិរសាបង្គំផ្ចង់ ព្រះរូបប្រសើរទ្រង់
ប្រោសសត្វផងឯក្រោយណា ។

២៤. ស្រេចន័យនឹងថ្វាថ្វេង ចរចាចែងសរសើរមហា ប្រាសាទទាំងប្រាំប្រា
កដកបកពិចិត្រក្រៃ ។

២៥. ប្រាសាទនេះឯងណា ព្រះឥន្ទ្រាទិព្វទេពថ្ងៃ ប្រើព្រះពិស្ណុការនៃ
ចុះមកកថ្វាយក្សត្រា ។

២៦. កាល្ពោះអស្ចារ្យក្រៃ មានក្សត្រិយ៍ថ្ងៃសោយរាជា ស្តេចទ្រង់ព្រះនាមា
ហៅព្រះបាទវង្សអស្ចារ្យ ។

២៧. ស្តេចមានព្រះអំណាច សេពសោយរាជ្យនូវធម្មាំ គ្រប់គ្រងអស់រាស្ត្រណា
សឹងក្សេមដោយព្រះបារមី ។

២៨. ស្តេចមានវរជាយា ទ្រង់នាមាទៃវតី ឆោមឆាយស្រស់សោភី
ជាច្បងច្បាស់អស់ស្នំផង ។

២៩. អនេកនូវបរិពារ ស្រីស្រីង្គាឥតឯផ្គង ស្រីស្រស់ទន់ទងវង
រៀបរាយរៀងបំរើនិត្យ ។

៣០. ព្រះមហាក្សត្រិយ៍ត្រកូល ជាឥស្សរអង្គឯកក្សត្រិយ៍ សឹងមកប្រណិប័តន៍
ថ្វាយបង្គំឥតឯផ្គង ។

៣១. សឹងនាំភ្ញីប្រាក់មាស ច្រើនដេរដាសដោយពណ៌ហោង ដ៏ថ្វាយនូវស្នួយផង
ជាប្រក្រតីពុំដែលអាក់ ។

៣២. អនេកនូវទ្រព្យផង រតន៍កែវកងនូវមាសប្រាក់ ព្រំព្រៃវិស័យចាក់

ខៀនក្រឡាកាសាច័ន្ទ ។

៣៣. អនេកនូវដំរី រថពាជីរាជាយាន្ត ក្ញីងក្ញស់នូវពិតាន
រាំងននរនៃបមាសមាលា ។

៣៤. អនេកនូវរេហ៍ពល ទាំងសាកលសែនយោធា ខុណាងមន្ត្រីត្រា
គ្រប់គង់គាល់ច្រើនក្រាស់ក្រៃ ។

៣៥. ស្តេចមានព្រះរាជាបុត្រ ប្រុសពិសុទ្ធពិសេសក្រៃ ប្រសើរព្រះនាមនៃ
ហៅព្រះកេតុមាលាហោង ។

៣៦. រីព្រះរាជកុមារ បុណ្យសម្ភារក្រៃកន្ទង ឮទូរសព្ទសាយហោង
អស្ចារ្យកើតកាល្ពោះណា ។

៣៧. កក្រើកដាលដួចដល់ ស្ថគ៌សាកលត្រៃត្រឹង្សា សម្តេចព្រះឥន្ទ្រា
បើកទិព្វចក្ខុមើលមកហោង ។

៣៨. យល់ព្រះរាជកុមារ មានសម្ភារក្រៃកន្ទង ជៀងជាក់ជាច្បាស់ច្បង
លើសលែងលុងលើក្សត្រា ។

៣៩. ដឹងដើមបុត្របូរាណ ចុះចាកស្ថានត្រៃត្រឹង្សា យកបដិសន្ធិជា
បុត្រព្រះបាទវង្សអស្ចារ្យ ។

៤០. សម្តេចព្រះឥន្ទ្រធ្យាន ដឹងដោយញាណឯងអស់អាថ៌ ជៀងជាក់សោះសព្វសារ-
ពើពិតពុំសន្ទិះឡើយ ។

៤១. ទើបស្តេចចុះចាកស្ថាន ស្ថគ៌ភីមានពុំលង់ឡើយ យករាជកុមារហើយ
នាំទៀងទៅត្រៃត្រឹង្សា ។

៤២. ព្រះឥន្ទ្រស្តេចសន្ធត់ ជាក់ជាបុត្រព្រះអង្គណា ស្រឡាញ់ថ្នមរក្សា
ហាក់កើតពីឧទរា ។

៤៣. កាល្ពោះទេពស្ថគ៌ស្ថាន នៅពុំក្សាន្តសប្បាយណា សឹងឈឺព្រះសិរសា
ដ្បិតធុំក្លិនមនុស្សវិស័យ ។

៤៤. ទេព្តាផងរំជួល សឹងខ្សឹកខ្សួលជាទុក្ខក្រៃ ពុំអាចទប់ទីទៃ
ឡើងទៅទូលព្រះឥន្ទ្រា ។



៤៥. បរពិត្រទេពឥស្វរ ជាកំពូលលើសិរសា ដោយច្បាប់ស្ថានស្ថគ៌ា
ពុំដែលមានដូច្នេះនៃ ។

៤៦. នាស្តេចយាងយោនយក បុត្រមោះមកស្ថគ៌ាលៃ យើងខ្ញុំផងទីទៃ
ធុំក្លិនមនុស្សនៅពុំក្សាន្ត ។

៤៧. នោះទើបព្រះឥន្ទ្រា- ធិរាជាបន្ទូលថ្កាន ថាហេតុបុត្របូរាណ
អញឯងហោងទើបនាំមក ។

៤៨. បើដូច្នោះកុំតឹង ជាទុក្ខនឹងបុត្រពន្ទក អញបានជាយកមក
ហើយអញនឹងជូនចុះទៅ ។

៤៩. កាល្ពោះឯក្សត្រា កេតុមាលារាជចោមចៅ អាល័យដ្បិតធ្លាប់នៅ
ប្រាសាទទាំងប្រាំសមស្រេច ។

៥០. នាមហៅពេជ្រយ័ន្តរថ ចិញ្ចែងក្តាត់សមក្សួរក្សាច់ ព្រោងប្រុះឆ្នុះរំលេច
ប្រាលប្រវាត់យល់សព្វសាយ ។

៥១. ដាំដាសពាសនីទៅ រតន៍ឆ្នុះឆ្លៅមាសព្រោងព្រាយ មរកតកែមពិទាយ
ពេជ្រពពាលរតន៍រៀងរាល់ ។

៥២. ពិទូរ្យស្ថូរ្យកាន្តកែម និលលក្ខណ៍លែមកែមកបកាល បូទមប្រាក់ៗពណ៌
មុក្តាដាច់ផ្ទេករតន៍រាយ ។

៥៣. ទទឹមទឹពស្រស់ស្រិល ឥន្ទ្រនិលតារាកាយ ពិទ្រុមទ្រុឌសព្វសាយ
កញ្ចក់ថៃមមាសមណី ។

៥៤. ប្រាក់ប្រុះឆ្នុះព្រោងព្រាយ សែងស្ថូរ្យសាយទ្ធូវបក្សី រួតរាក់ឆ្នាក់ទ្ធូវភ្ញី
ល្អប្រសើរឥតផ្ទឹមបាន ។

៥៥. រុងរឿងថ្កើងល្អស្រស់ ដោមខ្ពង់ខ្ពស់ប្រាសាទស្ថាន មួយពាន់យោជន៍ប្រមាណ
ពីកំពូលទៀងទាល់ក្រោម ។

៥៦. កំពូលកំពស់ស្រួច ស្រោងត្រដួចត្រដឹងដោម ត្រដាច់កណ្តាលព្យោ-
មាអាកាសវេហាសហារ ។

៥៧. ឯក្នុងប្រាសាទស្ថគ៌ សឹងរំយោលពិតានដា ភ្ញីប្រុះឆ្នុះរន្ទាល

ទ្ធវសុវណ្ណរតន៍រៀងរាយ ។

៥៨. រំយោលទងមាលា ទ្ធវបុប្ផផងទាំងឡាយ រន្ទាលភ្ញីព្រោងព្រាយ
ផ្សព្វនីទៅទ្ធវក្លិនភ្ញី ។

៥៩. ត្រសាកត្រសៀកល្វេង ស្នូរស័ព្ទភ្លេងភ្ញាត់តន្ត្រី របាំរបៀបស្រី-
ទេពអប្សររេរាំថ្វាយ ។

៦០. បវរវរសោភា អស់អង្គាទ្រង់ឆោមឆាយ ស្រឡះអង្គកែក្រាយ
ផ្ទៀលផ្ទាត់ផ្ទាយស្រួលឥតឆ្គង ។

៦១. បវរវរជួបចាប់ ទ្រង់គ្រឿងគ្រប់ប្រដាប់ផង សឹងស្រស់ៗទងវង
ទាំងបួនអង្គល្អប្រពៃ ។

៦២. សំរាប់ព្រះឥន្ទ្រា ចោមទេវាប្រសើរក្រៃ សេពសុខសម្បត្តិត្រៃ-
ត្រឹង្សពិភពសួគ៌ាលៃ ។

៦៣. មើលមានកាលប្ញព្រឹក្ស សោតសន្ទឹកខ្ពស់ត្រឈៃ ខ្យល់បក់ល្វន់ល្វាសក្រៃ
មែកស្ទោមស្លឹកប្រសព្វគ្នា ។

៦៤. គន់ទៅនន្ទឧទ្យាន សប្បាយក្សាន្តក្នុងចិន្តា សម្រាប់អង្គឥន្ទ្រា
ជាឆ្នើមឆ្នួតអស់ទេពផង ។

៦៥. រីអស់ទេពកញ្ញា តែងឧស្សាហ៍នាំគ្នាផង ច្រៀងច្រូចស្នូរស័ព្ទកង
លេងសព្ទដោយតូ្ទទៃ ។

៦៦. មានទាំងដើមបរិឆត្រ ខ្ពស់ដោមខ្វាត់មែកត្រឈៃ កំពស់ស្រោងល្វតលៃ
ហាសិបយោជន៍បរិមណ្ឌល ។

៦៧. ទ្រង់ផ្កាវង់ដូចឆត្រ ក្លិនក្បែបខ្វាត់រយយោជន៍យល់ ទេព្តាផងរវល់
សេពសោយសុខក្លិនបុប្ផ ។

៦៨. ពុំដែលនឹងល្ហិតល្ហៃ ជាសុខក្រៃក្នុងអាត្មា មានអស់ផ្កាបរិវារ
ផុះជាជួររៀបរៀងរាយ ។

៦៩. ខ្ទឹងក្ទម្ពកែកាកេស ក្លិនពិសេសធំភាសភាយ រំចេកកាកែសលាយ
ផ្កុលភ្ញដាន់ទ្ធវមហាហង្ស ។



៧០. ពុតផ្ញើរកពាក់ព័ន្ធ ផ្កាអញ្ចន់ក្រអូបហ្វង់ រំដួលទ្ធវត្រយ៉ង់
មែកពាន់ពាក់ដើមចម្ប៉ា ។

៧១. ច័ន្ទមានលុង្គែ ផុះបង្អែរទ្រង់បុប្ផ ស្រឡិតស្រឡីច្បារ
សអន្ទច្រាលខៀវអន្ទង ។

៧២. ក្តាំងងាទ្ធវសុរភី ទ្រង់សឹងភ្ញីស្រស់ៗជ្រង លតាមាសទន់ទងវង
វារពាក់ព័ន្ធផ្កាន្ទនស្រី ។

៧៣. មង្រ្គដើមប្ញក្ទាប់ ស្រស់ស្រេចស្រាប់មានរស្មី រំដេញមាសរីកថ្មី
នែបដាវរៀងលឿងក្រសែត ។

៧៤. អស់នាងទេពអប្សរ សឹងស្មោះសរអរអនេក ហែលហារបេះផ្កាចែក-
គ្នាក្រាលក្រងប្រដាប់អង្គ ។

៧៥. ខ្វះក្រងផ្ការំដួល រៀបជាជួរល្អបញ្ចង់ កើតឡើងដូចរូបហង្ស
គាងបក្ខារេហើរហោះ ។

៧៦. នាងមួយជណ្តប់ស្បៃ ស្តើងប៉ប្រែដើរផ្ទេកផ្ទោះ បេះផ្កាដោយចន្ទោះ
ផ្កាម្លិះរួតទ្ធវម្លិះលា ។

៧៧. ក្រងជារូបកិន្នរី ល្អពិសីមៀងមើលគ្នា នាងមួយមុខសើរ៉ា
ក្រងជារូបសោមបណ្ឌិត ។

៧៨. ខ្វះក្រងជាសារិកា- កែវពាំផ្កាហើយហើរជិត នែបនិងសោមបណ្ឌិត
ទំផ្លុងផ្ទៀងមៀងមើលគ្នា ។

៧៩. សឹងតែច្រៀងលេងសើច ខ្ញៀវក្ញាក់ខ្ទើចគ្រប់គ្នីគ្នា និយាយហើយពណ៌នា
សរសើរបុណ្យអង្គកោសី ។

៨០. នាងខ្វះល្អឧត្តម យល់សំណមស្រស់ប្រិមប្រិយ អ្នកនាំអស់ទាំងស្រី
ទេពអប្សរចុះស្រះស្រី ។

៨១. ខ្វះហែលបេះផ្កាស្តន់ ល្អទន់ភ្ញន់សកំផ្ញង់ លាយនិងផ្កាលំចង់
ផ្កានិលបុលទ្ធវស្បង់កាច់ ។

៨២. ខ្វះសោតល្អស្រងៅ ផ្ញេញស្រស់ខ្មៅហែលរដាច់ ដល់ហើយដៃកាន់កាច់

ផ្កាក្រមុទទូវឈូកសែត ។

៨៣. បង្គួតបង្គុា ហែលវេរាត្រដោមដែត វាយទឹកលេងដោយហេតុ
រាល់ដើមផ្កាឈូកសផង ។

៨៤. បេះបានស្រេចកែក្រាយ លេងសប្បាយក្នុងស្រះស្រង់ នាងខ្លះហែលតម្រង់
បេះកាច់ឈូកក្នុងជលសា ។

**នេះបទកាកគតិ**

៨៥. ព្រះកេតុសូរ្យវង្ស មៀងមើលរូបទ្រង់ អស់នាងកញ្ញា សើចលេងក្អាកក្អាយ
សប្បាយណាស់ណា មុខគួរស្នេហា ទូវនាងទាំងឡាយ ។

៨៦. ស្ដេចគិតអាឡោះ អាល័យស្រណោះ ពុំចង់ឃ្លាតឆ្ងាយ គន់គិតជញ្ជឹង
រំពឹងសព្វសាយ វែងគិតវែងស្ដាយ ពុំចង់ឃ្លាតឃ្លា ។

៨៧. រីអស់ទេពផង នាំគ្នាត្រសង ក្រាបទូលឥន្ទ្រា ឱ្យស្ដេចឆាប់នាំ
បុត្រស្ងួនពុំងា រួសរាន់មីម្នា មិនឲ្យយូរលង់ ។

៨៨. រីព្រះឥន្ទ្រា ចោមចៅទេវា អម្បូរពូជពង្ស អាសូរបុត្រស្ងួន
ខ្ញុំមខ្លួនវរវង្ស កប្បូរកបទ្រង់ លើសលែងនាៗ ។

៨៩. ទើបស្ដេចឆ្លាសឆ្លើយ ថាហៃទេពអើយ កុំគិតសង្ការ អញនឹងនាំបុត្រ
បរិសុទ្ធពុំងា ចរចាកឃ្លាតឃ្លា រួសរាន់ទៅហោង ។

៩០. ស្ដេចលោមបុត្រា ថាស្ងួនស្នេហា សំឡាញ់ស្នេហ៍ស្នង អាពុកឱ្យជូន
កូនស្ងួនទៅហោង ឥឡូវជាម្ដង ឥតឯរុញរា ។

៩១. ចៅកេតុសូរិយោ ពិសេសសេដ្ឋោ ឆ្នួតឆ្នើមលោកា លើកករបង្គំ
ប្រណម្យបិតា ទើបក្រាបទូលថា បពិត្រម្ចាស់ថ្លៃ ។

៩២. ឆ្នើមអស់លោកា ច្បងលើទេវតា នៅនាស្ថានត្រៃ- ត្រឹង្សាពិភព
ស្ងួគ៏សក្ដិសព្វថ្ងៃ ចិត្រខ្ញុំអាល័យ ពុំចង់ឃ្លាតឆ្ងាយ ។

៩៣. សម្ដេចចក្ខុន្ទ្រីយ ចោមចៅនរិន្ទ្រ ស្ដាប់បុត្រដោមឆាយ ថាផ្សិតស្រណោះ
អាលោះស្ថានអាយ ស្រួលសុខសប្បាយ ឥតឯគណនា ។

៩៤. ទើបស្ដេចឆ្លាសឆ្លើយ ថាហៃស្ងួនអើយ កុំថប់រុញរា និងពិភពស្ថាន



ភិមានសួគ៌ា អាពុកផានា សាងឱ្យអ្នកថ្លៃ ។

៩៥. រីបុត្រស្នេហា ស្ដែងស្ដាប់បិតា សារសងស្ងួមៃ បើកនិស្ស័ប្រិម
ញញឹមប៉ប្រៃ និងព្រះចោមត្រៃ ជាតិជាបិតា ។

៩៦. បើស្ដេចអាសូរ មេត្រីអនុក្ចល អញខ្ញុំករុណា សូមស្ដេចយកស្ថាន
ភិមានទេវតា ស្ពាងតាមសញ្ញា ចិត្រខ្ញុំបំណង ។

៩៧. ព្រះឥន្ទ្រឆ្លាសឆ្លើយ ថាហៃកូនអើយ កុំគិតឡើយហោង បិតានឹងយក
ស្ថានត្រៃត្រឹង្សា ស្ពាងឱ្យអ្នកហោង កុំស្ងួនបារម្ភ ។

៩៨. សម្ដេចទេវោ ប្រសើរវរោ ថ្វាថ្ងៃស្ងួស្ដីសម ស្ដេចលោមបុត្រស្ងួន
ខ្ញុំមខ្លួនឧត្ដម មិនឱ្យបារម្ភ អស់កិច្ចការផង ។

៩៩. ទើបព្រះកេតុឆ្លើយ ថាអម្ចាស់អើយ ខ្ញុំអរពេកហោង សូមស្ដេចប្រណី
ឃ្លាតខ្ញីជាម្ដង ហៅអស់ទេពផង មកធ្វើមីម្នា ។

១០០. រីព្រះទេវោ ជាតិជាអគ្គោ ស្ដាប់បុត្រពុំងា បុត្រចិត្រចង់ឆាប់
ប្រញាប់មហិមា ស្ដេចរៀបដោយនា ហប្ញទ័យចំណង់ ។

១០១. ឱ្យអស់ទេវតា តាក់តែងសព្វសា- រពើការផង ទាំងព្រះចតុល្ទោក-
កបាលហោះផ្សង ភ្ញុំពលស្រេចហោង ទេវបុត្រទេវតា ។

១០២. គិតគន់ឱ្យយក ពេជ្រយ័ន្តនោះមក សាងឱ្យបុត្រា យង់យល់ធំខ្ពស់
ពាន់យោជន៍សោះសា អស់ទាំងទេព្ដា ស្ញប់ស្ញែងទីទៃ ។

១០៣. សម្ដេចសក្កោ ប្រសើរសេដ្ឋោ រំពឹងរំពៃ និងព្រះពិស្ណុកា
ប្រាជ្ញាឆ្លៀងវៃ យល់ល្មមតែន័យ ស្ថានតែងជំនុំ ។

១០៤. ឈ្មោះហៅរោងធម៌ សភាឧត្ដម ទេវតាជួបជុំ នោះល្មមឱ្យសាង
គ្រាន់និងបន្ទុំ បារមីមូលជុំ ឯមនុស្សលោកា ។

១០៥. គិតព្រមស្រាប់ស្រេច ទៀងទើបសម្ដេច សហស្សចក្ខា អស់បរិពារផង
សែនកោដិសំខ្យា ទេវបុត្រទេវតា ចុះមកជាម្ដង ។

១០៦. សាងទាំងព្រះគោ ប្រសើរវរោ អង្គមួយមកផង ជាអ្នករក្សា
ទីស្ថានសព្វផង កុំឱ្យហៅហ្មង ដល់រាជបុត្រា ។

១០៧. កាលស្តេចនាំបុត្រ   វិសេសវិសុទ្ធ   មកដល់ហើយណា   ឱ្យព្រះវិស្សកម្ម
ឯងអាចត្រួតត្រា   អស់ទាំងបរិបាល   ពិភពស្ថានផង ។
១០៨. ទើបឱ្យកែនពល   រវាតរវល់   វឹកវរអឹងកង   ប្រាំពីលរង្វាស់
នគរធំផង   បានស្រេចហើយហោង សព្វបរទេសា ។
១០៩. ខ្មែរសៀមភូមា   មនលាវលន្វា   ផ្សាចាមលង្កា   យួនចាស់កែសើន
ច្រើនណាស់ត្រៀបត្រា   ការៀងហង្សា   ទាំងភ្ជីងខែកខ្លាំង ។
១១០. បាវាំងស្មៀងព្នង   ទុំព្វនព្នងផង   ច្រើនក្រៃត្រឡាំង ចិន្តកហុកកៀន
តជីវកោយតាំង   ទាំងក្ទួយស្ទួនផ្លាំង   ហៃយហុងតាំងកៀវ ។
១១១. ជប៉ុនឈៀងម៉ៃ   រំខើងក្រាស់ក្រៃ   មមើកគតៀ   ទាំងក្ទួយពាណិជ
ខែកក្ទូលាប្បៀ   ក្ទួយដែកកន្ទៀល   រដាកសៀមផង ។
១១២. លង់លុះផ្ទុំស្រេច   កាល្ពោះទើបស្តេច   ចេញចរទៅផ្លង ទុកអស់ទីស្ថាន
ដោយដានទំនង   ព្រះគោឈប់ផ្លង   អគ្គេយ៍បូព៌ា ។
១១៣. នៃភ្នំបាខែង   ស្រួលបួលជាក់ស្តែង   ព្រះវិស្សកម្មា ឱ្យប្រាប់ទីស្ថាន
ដកអស់ព្រឹក្សា   ស្បូវស្បាតបន្ទា   ជ្រះស្រេចហ្មត់ហ្មង ។
១១៤. ទើបឱ្យយកថ្ម   សិលាសីងល្អ   ប្រសើរកន្ទង   រណ្តាប់វាស់វែង
ខ្ទាត់ខ្វែងជាម្តង   ស្រួលស្រេចហើយហោង ទើបប្រដាប់ក ។
១១៥. ជាប្រាង្គប្រាសាទ   ល្អល្អះស្អាងស្អាត   សុទ្ធសីងតែថ្ម   មានរោងជំនុំ
ទាំងស្រះបួនល្អ   ហៅត្រៃសឹងថ្ម   ឆ្វេងស្តាំផងណា ។
១១៦. រោងទងខ្ទាត់ខ្វែង   រោងជ្រៀកយល់ស្តែង ទាំងរោងក្រឡា បន្ទំជាក់ស្បាន់
មានច័ន្ទជាយា   ទល្ហរចាំងច្រាល   មុខដាច់ត្រឡែង- ។
១១៧. -កែងគាប់ឧត្តម   មុខនាគបន្សំម   ភ្ជាក់ដៃខ្ទាត់ខ្វែង ក្លាយជារូបសិង្ហ
ប្រៃប្រឹងសំញែង   ស្មើញស្វាញយល់ស្តែង   ហាក់រស់វិស័យ ។
១១៨. ប្រាសាទប្រាំបួន   រុងរឿងថៃថ្កូន   ឆ្នោវធ្លាក់ក្រាសក្រៃ ភ្ញីវល្លិ៍ល្វកលាក់
ហាក់ដូចស្ថានត្រៃ   ត្រឹង្សត្រិមវិស័យ   មុខគួរអប្បមាណ ។
១១៩. បល្ល័ង្កទ្រាប់ខ្សាច់   ក្បាលពេជ្រសម្រេច   ក្លាយជាបក្សា គ្រុឌយក្សគន្ធព្វ



ទ្រផ្ទប់ក្រឡា   ក្លាយបែកជាផ្កា   ឈូកផ្កាប់ស្ទួនសម ។
១២០. មានរូបបីជាន់   ល្អល្អះគ្រប់គ្រាន់   ត្រសោលត្រសម   ជាសាវពើវស្វត
រហូតដល់កំ   ពូលពេជ្រឧត្តម   បាកានទាំងប្រាំ ។
១២១. មើលទៅស្រោងស្រីង   ត្រដូចត្រដឹម   ជុំនាងវិលតាម   ល្អល្អះថៃថ្កូន
សំនួនស្ទួនសម   មើលយល់ជាក-   ម្រអ្នកឯណា ។
១២២. នឹងធ្វើគ្រាប់បាន ហេតុបុណ្យបូរាណ   សែនសោតសំខ្យា ដោយបុណ្យសម្តេច
សហស្សចក្ខា   និងបុណ្យបុត្រា   អម្បូរព្វជពង្ស ។
១២៣. នោះនៃទើបបាន   រណ្តាប់ជាស្ថាន   ស្តេចស្តែងគួរគង់   ឯស្តេចឯករាជ
ខូបខ្វាចពុទ្ធពង្ស   កប្បូបកបទ្រង់   ឆ្នួតឆ្នើមក្សត្រិយ៍ផង ។
១២៤. គន់មើលទ្វារប្រាង្គ   វិស្ណុការសាង   សក្តិសមក្តាត់ហោង ប្រាំពីររួតរតន៍
ពេនព័ទ្ធភ្ញីផង   ក្លាយក្បែបម៉ង្គហ្វង   ជាក្បាលព្វរា ។
១២៥. បាកានទាំងបួន   រួតប្រាំជាន់ជួន   ចែកជាមុខរាហ៍ ក្នុងក្អក់សីងក្បាច់
ស្រស់ស្រេចដូចគ្នា   ព្រះកេតុមាលា   មានបុណ្យស្ងប់ស្ងែង ។
១២៦. វីព្រះវិស្ណុការ   រណ្តាប់សព្វសារ-   ពើការកំប្លែង   ជារូបកញ្ញា
កាន់ផ្កាដៃឯង   ខ្វះកាន់កន្សែង   ឈរដោយចន្ទោះ ។
១២៧. ក្បែរល្ងហ៍ជុំជាក់   ក្លាយជារូបយក្ស រូបគ្រុឌស្នានស្នោះ ឈរឈានចាំទ្រង់
ដោយទរឥតខ្ទោះ   របបរបស់   គ្រប់ផ្ទាំងនោះណា ។
១២៨. គន់មើលគាងឃ្វាយ   ត្រីស្ទូល័ពន្រាយ   សីងកែវមុក្ខតា   ពិទូរ្យពិទាយ
រៀបរាយសោភា   ក្រតិតគណនា   ក្រស្តាប់សព្វសាយ ។
១២៩. កំពូលស្រួចស្រុង   ធ្លាក់ក្បាច់សំយុង   កញ្ចក់ព្រោះព្រាយ ត្រដែតត្រដូច
ស្រោងស្រួចយល់ឆ្ងាយ   ភ្ញីព្រោងក្បោះក្បាយ   កណ្តាលវេហាស៍ ។
១៣០. ផ្ទះផ្ទោងមុខដាច់   សម្រួលសម្រេច   ដងក្តារជហ្វា កែបកាលក្អក់ពេជ្រ
សីងលេចបន្ទា   ឆ្វៅឆ្វាស់លតា   ភ្ញូតាន់ទាំងទង ។
១៣១. សសរស្តម្ភទ្រង់   ក្រោមក្រាសសីងថ្ម   ភ្ជាក់ដែសងខាង ធ្លាក់ឆ្វៅក្បូរក្បាច់
សម្រេចឥតឆ្លង   ជ្រុងជ្រោយសោតហោង   លកល្ងសល្អក្រៃ ។

១៣២. ហាក់ដូចក្រឡា ជំនុំទេវតា នៅសួគ៌ាលៃ សំរាប់ព្រះឥន្ទ្រ
និន្ទ្រចោមចៅ ត្រឹងព្រាសួគ៌ាលៃ ល្អឥតគណនា ។

១៣៣. ប្រដាប់ជាស្ពាន ក្លារបែនសោតមាន បសិ្ចមទិសា រោងរម្យកក្ខាត់
ស្អាងស្អាតសោភា សឹងថ្មសីលា ប្រកិតក្រាសក្រៃ ។

១៣៤. ប្រដាប់ក្រឡា- បន្ទំសោភា ផ្ទេងស្កំប្រពៃ ស្រណុកសប្បាយ
លោះលាយពេកក្រៃ ហាក់សួគ៌ាល័យ ទិព្វទេព្វទេវា ។

១៣៥. ត្រង់ទ្វារចូលទៅ ប្រដាប់លំនៅ មហារាជមហិមា កជាប្រាសាទ
ស្អាងស្អាតរចនា ឆ្លាក់ជាភ្ញីផ្កា រំយោលឆ្លាត់ឆ្លាយ ។

១៣៦. ឆ្លាក់ជាទេព្រក្ស រឹងឫទ្ធិសិទ្ធិស័ក្តិ ឈរឈមរៀងរាយ ខ្វះកាន់ដំបង
ផ្ដាប់ផ្គងហាក់វាយ ក្រទាករកាយ នែបនៅមាត់ទ្វារ ។

១៣៧. ទ្រង់នាមមេ-ស បពេជ្ជឥទ្ធិវ រឹងឫទ្ធិឥទ្ធា តែងនៅពិភក្ស
រក្សាព្យាបាល ខេត្រខ័ណ្ឌច័ក្រវាឡ ឥន្ទ្រប្រស្នូនគរ ។

១៣៨. ស្ដេចអាចក្រវើន និត្យនៅចំរើន សួស្តីឫទ្ធីពរ មនុស្សផងនា។
យាត្រាចេញចរ ចូលក្នុងនគរ ទិព្វស្ថាននោះណា ។

១៣៩. សិងប្រុងប្រដាប់ ស្វាម្ទសម្រាប់ ទៀនធូបភ្ញីផ្កា អស់ភោជនផង
គ្រប់គ្រងបូជា អធិដ្ឋានប្រាថ្នា សូមជនជួយជ័យ ។

១៤០. ហើយលោកប្រដាប់ ឆ័ត្ររួតសំរាប់ មហារាជនោះនៃ នាមហៅជីទេព
និត្យនៃបប្រពៃ មនុស្សផងសព្វថ្ងៃ តែងទៅប្រាថ្នា ។

១៤១. សូមដោយចំណង់ អនុពាលចិត្តចង់ សម្លាញ់ស្នេហា ជីទេពឯងឲ្យ
តាមដោយចិន្តា ដូចចិត្រប្រាថ្នា ពុំឃ្លាតឡើយហោង ។

១៤២. ព្រះវិស្ណុការ ជាជាងអស់សារ- ពើពុំឱ្យឆ្លង តែងបញ្ចប្រាសាទ
ស្អាងស្អាតកន្ទង ផ្ទផ្ទាំងនោះផង ជុំវិញវិលវ័ណ្ឌ ។

## បទពំនោល

១៤៣. ប្រដាប់បល្ល័ង្កប្រាំជាន់ ទ្រូតទ្រាប់ឧរ្យាច់ខ័ណ្ឌ សំអាងសំអាតពិព័រណ៌ ។



១៤៤. មានជណ្ដើរកាច់រៀងរាល់ ជ្រុងជ្រោយសឹងសារ- ពើស្វត្រប្រសើរសោភី ។
១៤៥. ផ្ទៅឆ្លាក់ក្បូរក្បាច់អស់ក្ដី ចម្លាក់ទងភ្ញី ប្រព័ន្ធប្រពាក់លើគ្នា ។
១៤៦. ឆ្លាត់ឆ្លាយបីបន្ទាយលតា រៀបរីកបុប្ផា មាលារំយោលសំយុង ។
១៤៧. គ្រួយគ្រួលបីបណ្ដូលចោមចង់ លេចទងបីរហង់ ជាផ្ទូរំយោលដកច័ន្ទ ។
១៤៨. ភ្ញីវាររាំងវាសវ័ណ្ណ ពេនពានពាក់ព័ន្ធ ប្រវ័ន្ធប្រទាក់ក្រាសជ្រោះ ។
១៤៩. ក្បែបក្បាយលេចលាយល្អូតលាស់ ច្រូងប្រាងបីប្រទាស់ ក៏ផ្លាសមណីពាធា ។
១៥០. ភ្ញីក្បាយលេចលាយផ្ទៃផ្កា ខ្ទាប់ក្បាយផ្ទៃជា រូបមនុស្សរេរាំកាងដៃ ។
១៥១. នារីស្រស់ស្រីដ៏ប្រពៃ ហាក់កើតឯងនៃ ក៏លេចពីក្បែបបុប្ផ ។
១៥២. ខ្វះក្បាយក្បែបជាមុខរាហ៍ ខ្វះក្បាយជាមហា ហែមហង្សប្រសើរបវរ ។
១៥៣. ខ្វះជានាគន្ទវម្ភរ ខ្វះជាគ្រុឌា ក៏ចាប់នាគាឆក់ស៊ី ។
១៥៤. ផ្ទៅឆ្លាក់ចម្លាក់អស់ក្ដី ក្បែបក្បាយជាភ្ញី ហាក់មានវិញ្ញាណរូបរស់ ។
១៥៥. ប្រាសាទប្រាំរួតស្រេចស្រស់ ថ្កល់ថ្កើងខ្ពង់ខ្ពស់ ត្រដឹងត្រដែតស្រោងស្រួច ។
១៥៦. ត្រីស្ទូល៍កុំព្ធលច្រូងស្រួច ដុងដោមបីត្រដួច ត្រដែតកណ្ដាលវេហាស៍ ។
១៥៧. ឆ្លាក់ឆ្លក់ត្របកបទុមា ក្បូរក្បាច់រចនា រំយោលសម្រាច់ស្អាតស្អាង ។
១៥៨. គាងឃ្វាយបីត្រដាច់ច្រូងប្រាង សីមាដាំខាង ត្រចៀកក្របីស្រស់ស្រេច ។
១៥៩. ជងក្លារពពារមុខដាច់ ផ្ទៅឆ្លាក់ក្បូរក្បាច់ រំលេចបុប្ផបីប្រពៃ ។
១៦០. មុខព្រហ្មសោតសមថ្កើងក្រៃ ទាំងបួនទិសនៃ ប្រាកដ្ឋប្រកបសាយសព្វ ។
១៦១. ផ្ទះផ្ទាំងបីជញ្ជាំងជួបចប់ ផ្ទះខ្វែងដ៏ប្រសព្វ នៅមុខសម្រាប់ឥតឆ្លង ។
១៦២. កាំឃ្នូរសីមាដាំខ្សង ស្វឹកខ្នុរនោះផង ក៏ដាំរំលេចជួរចារ ។
១៦៣. សសរស្ដម្ភទ្រវៀងរាល់ ជ្រុងជ្រោយសឹងសា- រពើស្វត្រប្រកិតរៀងរួច។
១៦៤. ផ្ទះផ្ទាំងជញ្ជាំងបង្អួច ជើងទៀនរាល់រួច ចម្លាក់ក៏ឆ្លាក់ល្អក្រៃ ។
១៦៥. ប្រដាប់ស្រាប់បីប្រពៃ ដំបូលនោះនៃ លើរួតប្រាសាទស្រាប់ស្រេច ។
១៦៦. ផ្ទះត្រលែងកែងមុខដាច់ សោតសឹងស្រស់ស្រេច ប្រាសាទផ្ទះរួតកណ្ដាល ។
១៦៧. ប្រាសាទទាំងបួនមានទ្វារ គ្រប់សព្វនូវប្រការ បន្ទាប់ទ្រាប់ត្រួតលើគ្នា ។

១៦៨. ផ្ទះផ្ទាំងជញ្ជាំងប្រាង្គប្រា- សាទសួគ៌សោភា ចម្លាក់ចំម្លៅអស់ក្តី ។
១៦៩. ឆ្លាក់ជារូបរតន៍នារី ហៅភោគ្គវតី គឺស្រីប្រសើរសួគ៌ា ។
១៧០. រូបទ្រង់បញ្ចង់សោភា ឈរឈមរៀងគ្នា លេងលើប្រាសាទសោតហោង ។
១៧១. ខ្លះទម្លលសសួលឥតហ្មង ទន់ភ្លន់មុខឈ្មង ប្រកបនូវលក្ខណ៍ចានខ្នាត ។
១៧២. ផ្ទួតចារភ្ញីញារស្លាងស្អាត ខ្លះបួងខ្លះកាត់ កែមកាលកេសាសោតសម ។
១៧៣. ចង្កេះរៀវឆៀវម្ទូលក្ងំ ដោះសោតសឹងក្បំ ក៏ដូចក្រពុំបទុមា ។
១៧៤. ស្រឡះសជ្រះអង្គា សឹងពាក់មាលា គន្ធារភមរាកាឡី ។
១៧៥. ចងនូវចំណងកេសី ពេនព័ន្ធទងភ្ញី ស័ក្តិសមបន្ទាយល្អក្រៃ ។
១៧៦. ខ្លះដោតខ្លះក្រងដ៏ប្រពៃ ខ្លះទើបយកដៃ សិកសៀតកាន់ក្រងឆ្វាត់ឆ្វាយ ។
១៧៧. ខ្លះសោតសិតសក់បន្ទាយ ខ្លះសោតកាន់ជាយ សំពត់ក៏ទាក់ឡើងផង ។
១៧៨. ខ្លះកាន់ភ្ញីសួគ៌ទាំងទង ខ្លះកាន់នៅកម្រង ភ្ញីទេសទាំងទងលតា ។
១៧៩. ខ្លះផ្ទៀងឈ្មងឈ្ងៀងមើលគ្នា ខ្លះចូលប្រវារ កាន់ស្វាដណ្តើមទងភ្ញី ។
១៨០. ខ្លះសើចញញឹមប្រិមប្រិយ ហាក់នឹងស្រដី សំណេះសំណាលរួមរក្ស ។
១៨១. បើគន់មើលទៅលុះជាក់ ព្រឺព្រួចភ្ញាភ្ញាក់ ស្រមៃស្រមោលម្តងៗ ។
១៨២. ហាក់នឹងស្រដីមកផង ដំបូចផ្តោះផ្តង ដាក់មុខលំញ៉ឹងចងចិត្រ ។
១៨៣. មៀងមើលទៅហើយហាក់ពិត ខ្លះដើរកាន់ផ្ចិត ខ្លះកាន់សត្វសេកផងណា ។
១៨៤. បន្ទំនៅលើទងផ្កា ខ្លះកាន់បទុមា ទូវផ្កាកំភ្លឹងទាំងទង ។
១៨៥. ស្បែកខៀនខ្នប់ចង្កេះផង អន្ទាមសុរ៉ង កញ្ជ្រិលប្រដាប់គ្រប់គ្រាន់ ។
១៨៦. សឹងពាក់កងជើងពីរជាន់ ខ្សែដេរវ័ណ្ណ រំលេចនូវល្ងសទងភ្ញី ។
១៨៧. សឹងស្អាងរូបរាងសោភី គ្រប់គ្រឿងអង្គស្រី កញ្ចក់ចិញ្ចៀនព្រះទម្រង់ ។
១៨៨. ប្រដាប់គ្រប់គ្រឿងបញ្ចង់ ឈរឈមមីរហង់ ស្រលូតស្រឡះអង្គា ។
១៨៩. ហាក់ដើរយាងយាសយាត្រា អែនអនរេរា រញីករញ៉ក់ផ្សារស្រី ។
១៩០. ទងវងញៀងញ៉ងប្រិមប្រិយ ហាក់នឹងស្រដី សំណេះសំណាលស្នេហា ។
១៩១. អនង្គិនលំទោនអង្គា ចុកចងសិរសា បង្កៀកបង្កាច់សុរង ។
១៩២. ប្រែប្រួលមិត្រម្ទូលផ្ទៀងផ្ទង វរវាសលំញ៉ង ទ្រទេសទ្រទន់ស្រួលស្រេច ។



១៩៣. ខ្លះចាប់របាំកែកាច់ កែក្រាយចាក់ក្បាច់ ក៏ទន់ល្វន់ល្វាសវិលវៃ ។
១៩៤. ល្អល្អះសះគ្រាសបីប្រពៃ ល្វាក់ល្វមល្ងិតល្វៃ ត្រឈៃត្រឆើតស្រួលស្រស់ ។
១៩៥. កែក្រាយរៀបរាយរៅរស់ ស័ក្តិសមនូវកំពស់ កំពុងទ្រង់អង្គពេញពាល ។
១៩៦. មៀងមើលយង់យល់ដ៏ត្រកាល កើតក្ងួចដល់ដាល ក៏ចងនូវចិត្តស្នេហា ។
១៩៧. ពុំឆ្អែតពុំឆ្អន់នេត្រា ត្រេកសោមនស្សា ពុំស្កប់ពុំស្កល់ចិត្តឡើយ ។
១៩៨. ចរចូលមៀងមើលជាក់ហើយ ពុំចង់ចេញឡើយ អាឡោះអាល័យពេកណា ។
១៩៩. ពុំយល់ជាថ្មសីលា លោកករចនា សម្រាច់សម្រួលដ៏ប្រពៃ ។
២០០. ហាក់ដូចរូបមនុស្សវិស័យ មើលហើយសង្ស័យ ស្រមុទពង់ពោះនិងនៅ ។
២០១. រូបទាំងមួយពាន់ឈរនៅ ល្អៗល្អេញល្អៅ ទាំងមួយពាន់ឥតមានខ្ចោះ ។
២០២. លោកឆ្លាក់ដោយនៅចំពោះ ដោយកៀនដោយកោះ
ដោយជ្រុងដោយជ្រោយផងណា ។
២០៣. ស្រណុកសប្បាយមហិមា ហាក់ស្ថានសួគ៌ា ភិមានត្រៃត្រឹង្សលើនាយ ។
២០៤. ផ្ទះផ្ទាំងជញ្ជាំងរៀងរាយ ឆ្លាក់ជានិយាយ ព្រះរាមកេរ្តិ៍កាលយាត្រា ។
២០៥. ទ្វារបរមយក្ខក្រៃណា ក្រិតយុគលុះមហា កលិយុគឥឡូវនេះនៃ ។
២០៦. កុំឲ្យមនុស្សផងសង្ស័យ ទុកកេរ្តិ៍ក្រោយក្រៃ អនេកនិយាយច្រើនជាតិ ។
២០៧. ឆ្មៅឆ្លាក់ជារូបព្រះបាទ វេស្សវ័ណ្ណនរនាថ ដ៏មានឫទ្ធីចេស្តា ។
២០៨. ច្បាំងនិងព្រះអាទិត្យមហិមា ស្តេចមានជ័យា ពន្ទឹកនូវឫទ្ធិគួរស្ញែញ ។
២០៩. ហើយឆ្លាក់ឆ្លក់ជាកំពែង បន្ទាយខ្វាត់ខ្វែង នគរស្រីឲ្យយុធ្យា ។
២១០. ឆ្លាក់ជាប្រាសាទសោភា រុងរឿងរចនា ទន្ទឹមមណ្ឌលរោងរម្យ ។
២១១. ឆ្លាក់ជាទីព្រះបន្ទំ មហាក្សត្រិយ៍ឧត្តម ព្រះបាទទសរថរាជា ។
២១២. ច្បងច្បាស់លើសអស់ក្សត្រា ជាព្រះបិតា ព្រះរាមទេពក្សត្រិយ៍ក្សាន្ត ។
២១៣. នគរនោះហៅទេពស្ថាន ខេត្រខែមហិមព្វាន ពព្វកឥសីសិលា ។
២១៤. ឆ្លាក់ជាព្រះច័ន្ទតារា ព្រះអាទិត្យសូរិយា រស្មីក៏ភ្លឺព្រោងព្រាយ ។
២១៥. ឆ្លាក់ជាសោឡសសួគ៌នាយ ឥន្ទ្រព្រហ្មសម្ពាយ នូវទេពនិករក្រាសក្រៃ ។
២១៦. ឆ្លាក់ជារូបព្រះឥសូរនៃ ស្តេចស្ថិតស្ថានឮ កៃលាសលើសលើទេវតា ។

២១៧. ច្រាលច្រាសនិរាសមរនា និរជាតិជរា ព្យាធិមន្ទិលទាំងឡាយ ។
២១៨. ឥន្ទ្រព្រហ្មយក្សយមសម្វាយ មីមូលមកថ្វាយ បង្គំប្រណមស្ទុស្តី ។
២១៩. សូមជ័យជោគជន្មឫទ្ធី ស្តេចមានមេត្រី ប្រសើរប្រជីពរហោង ។
២២០. ស្តេចជាពន្លឺលោកផង ទ្រង់សីលគ្រប់គ្រង មណ្ឌល់ត្រៃភពទាំងឡាយ ។
២២១. ឆ្លាក់ជារូបព្រះនរាយណ៍ ទ្រើសទ្រង់ឫទ្ធិសាយ ក៏គង់លើគ្រុឌរាជា ។
២២២. ហិចហោះផ្ចាញ់ក្រុងអសុរា កាលកាចវិនា វិនាសសូន្យសោះបាត់បង់ ។
២២៣. វៀងរាល់លុះទាល់ព្រះអង្គ ចាប់បដិសន្ធិទ្រង់ ជាព្រះរាមាទេពថ្លៃ ។
២២៤. ឆ្លាក់មហាឫសីកាឡៃ កោតឫទ្ធីក្រៃ ក៏នាំព្រះរាមនូវព្រះលក្ស ។
២២៥. ទៅប្រសិទ្ធិសីលធ្នូប្រត្យក្ស ឫទ្ធីសិទ្ធិស័ក្តិ ពន្លឺកពន្លឺមហិមា ។
២២៦. ឆ្លាក់ជារូបព្រះរាមា នូវព្រះអណុជា ក៏ស្តេចដើរទេសពនេចរ ។
២២៧. ពីរអង្គត្រេចត្រង់ព្រះនគរ មិថិលាដ៏បវរ លំនៅនៃនាងសីតា ។
២២៨. ឆ្លាក់ជាព្រះបាទមិថិលា ឲ្យអស់ទេវតា លើកធ្នូសហស្សធម៌ទ្រង់ ។
២២៩. ទេវតាពីរដណ្តប់អង្គ សោតសឹងតែទ្រង់ ជំនិះទីទៃអស់ក្តី ។
២៣០. ទេវតាខ្វះជិះដំរី ខ្វះជិះពាជី ខ្វះសោតជិះលើរាជហង្ស ។
២៣១. ខ្វះជិះក្ងោកពេនពុង ខ្វះសោតជិះអង្គ នៃគាល់សហស្សលៀងភារ ។
២៣២. ជិះរមាសជិះសិង្ហជិះខ្លា ខ្វះជិះយក្សា នាគាគន្ធព្វទាំងឡាយ ។
២៣៣. សឹងហោះចុះមកប្រញាយ ទីទៃខ្វល់ខ្វាយ សឹងលើកពុំបានឡើយណា ។
២៣៤. ឆ្លាក់រូបព្រះបាទរាមា ស្តេចមានចេស្តា ក៏លើកបានដូចបំណង ។
២៣៥. បាននាងសីតាដូចប៉ង មហិមាឯងហោង សំដែងនូវឫទ្ធិប្រាកដ ។
២៣៦. ឆ្លាក់ជាព្រះបាទទសរថ នាំព្រះរាជបុត្រ នូវបុត្រប្រសាត្រកូល ។
២៣៧. ពើបពះក្រុងរាពណ៍បរមឥសូរ ចុះមកពុំយូរ ប្រកួតប្រឡងចេស្តា ។
២៣៨. លីគ្រឿងព្រះទម្រង់ផ្ទាញផ្ទា នូវកៅទណ្ឌមហា នាគានូវនាគបញ្ចង់ ។
២៣៩. ស្តេចបានធ្នូនោះមន្តទ្រង់ កោះកាំបីតម្រង់ គីព្រហ្មាសវាយផ្ទាញផ្ទា ។
២៤០. ក្រុងរាពណ៍សូរកាម្មា លុះលុតវន្ទា បង្គំប្រណម្យព្រះអង្គ ។
២៤១. ឆ្លាក់ជាព្រះរាមស្តេចគង់ នៅស្ថានកំឡុង នគរស្រីឰយុធ្យា ។



២៤២. ហើយព្រះរាមនូវនាងសីតា ព្រះលក្សអនុជា ទាំងបីក៏ស្តេចចេញវៃ ។
២៤៣. ដើរទេសន៍ចេញចាកដល់ព្រៃ សូវធិកក៏ក្រៃ ត្រមោចតែបីអង្គា ។
២៤៤. ឆ្លាក់រូបមហាយក្សា វិរាធមហិមា ក៏ឆក់សីតានាំរត់ ។
២៤៥. ឆ្លាក់រូបព្រះលក្សប្រាកដ ស្ទុះតាមប្រយុទ្ធ ក៏បាននូវព្រៃព្រឹក្សា ។
២៤៦. ឆ្លាក់ជាព្រះរាមថ្វៃងសរ ភិវាត្តលុះមរណ៍ កណ្តាលនៃព្រៃព្រឹក្សាន្ត ។
២៤៧. ឆ្លាក់ជាព្រះលក្សប្រែប្រាណ លាបងបួសបាន ជាមហាឫស្សីថ្លៃថ្លា ។
២៤៨. ឆ្លាក់រូបនាងសូរបណក្ខា ស្វែងស្វះយាត្រា សំណាក់ព្រះបាទពីរពង្ស ។
២៤៩. ល្បួងលោមចរចាចោទចង់ ស្នោះស្នានព្រះអង្គ កក្រើកនូវកលមាយា ។
២៥០. ឆ្លាក់ជាព្រះលក្សក្រោធា ករកាន់ខ័នថ្វា ក្រវីសរហោះវិលវៃ ។
២៥១. ចិកសក់ច្រូតច្រំកាត់ដៃ អាស្រូវពេកក្រៃ ហៅមហាទុរយសមហិមា ។
២៥២. ឆ្លាក់ទោះផែនជាយអាសូពា មកយកបណក្ខា នាំទៅដល់ព្រះនគរ ។
២៥៣. ឆ្លាក់ជារូបមហាក្រុងខរ នាំពលវិកវរ ប្រញាប់ប្រយុទ្ធរឿងរុង ។
២៥៤. ឆ្លាក់ជាមហាក្សត្រិយ៍ពីរពង្ស ផ្ចាញអាសុរាបង់ វិនាសទាំងពលយោធា ។
២៥៥. ឆ្លាក់ជាមហារីកាឡា ជាប្រើសមាសមហា យាត្រានាខាងអាស្រម ។
២៥៦. ឆ្លាក់ជាសីតាឧត្តម លើកដៃបង្គំ អង្វរព្រះរាមរាជា ។
២៥៧. ឆ្លាក់ជារូបព្រះរាមា តាមប្រើសមាសណា ក៏ត្រេចក្នុងភ្នំគីរី ។
២៥៨. ឆ្លាក់រូបរាពណាធិបតី កាឡានូវឫទ្ធី ប្រែជាព្រាហ្មណ៍ព្រឹទ្ធិសិលា ។
២៥៩. ចូលឆក់រតន៍រាជសីតា ហោះដោយវេហាស៍ ច្រឡំនិងសូរិយាទៃ ។
២៦០. ឆ្លាក់ជាជតាយុឯងនៃ កាងស្លាបខ្ពស់ក្រៃ ស្រឡប់ងងឹតបាត់សុង ។
២៦១. ឆ្លាក់ជារាពណាទ្រើសទ្រង់ ពោះចិញ្ចៀនព្រះទម្រង់ ក៏ត្រូវចំអេងជតាយុ ។
២៦២. ចាក់ខ្វបស្រយាបធ្លាក់ចុះ ក្រុងរាពណ៍ហោះខ្ពស់ ក៏ដល់នគរលង្កា ។
២៦៣. ឆ្លាក់ជារូបព្រះរាមា ចាញ់ប្រើសកាឡា អសុរក៏លុះមរណ៍ក្ស័យ ។
២៦៤. ហើយឆ្លាក់ជាព្រះអង្គថ្លៃ វិលវិលមកនៃ ពុំឃើញទេវីពន្លិតា ។
២៦៥. ត្រមោចតែពីរអង្គា សែនសោយសោកា ក៏ស្តេចត្រាច់ចររកមហេសី ។
២៦៦. ផ្ទាំងមួយនោះសោតអស់ក្តី ឆ្លាក់ជាទូភី ប្រយុទ្ធប្រឡងនិងបា ។

២៦៧. ដើងផ្កៀងផ្លងវេរា ផ្តួលចាមរនា កណ្តាលលើមហាប្រថពី ។
២៦៨. ហើយឆ្លាក់ជារូបទូភី តនិងពាលី ៗឫទ្ធីលើសក្រៃ ។
២៦៩. ពាលីផ្តួលទូភីក្ស័យ និត្យនៅព្រះព្រៃ កំលុងបពិតគុហា ។
២៧០. ផ្ទាំងមួយនោះសោតឆ្លាក់ជា សុគ្រីពឯងណា ក្លូវគ្រងអស់មុខមន្ត្រី ។
២៧១. ផ្ទាំងមួយនោះសោតឆ្លាក់ជា ពាលីមហិមា ក្រទាស្អួយក្បាលទូភី ។
២៧២. ឆក់ឆាំងប្រឹងប្រាណដ៏ក្រវី ចោលក្បាលទូភី ទម្លាយទ្វូវទ្វារគុហា ។
២៧៣. ផ្ទាំងមួយពាលីក្រោធា និងសុគ្រីពរាជា ប្រយុទ្ធប្រយ័ត្នវិលវៃ ។
២៧៤. សឹងមានកម្លាំងទីទៃ ខាសខែងជាញជ័យ ប្រជួបប្រចាប់សោះសា ។
២៧៥. ហិចហោះករកាន់ខ័នថ្វា ពាក់ព័ន្ធទ្វូវត្ឋា កណ្តាលអាកាសនភី ។
២៧៦. សុគ្រីពចាញ់ដៃពាលី រត់ចូលគីរី នៃកម្មមកគង់បព្វតា ។
២៧៧. រីផ្ទាំងមួយនោះសោតណា ជាព្រះរាមា ស្តេចត្រាច់តាមរកព្រះមហេសី ។
២៧៨. ពើបពះពាន់យក្សអន្យត្ថិយ ស្តេចមានបារមី ក៏ផ្តួលនៃយក្សមរណា ។
២៧៩. ហើយឆ្លាក់ជាព្រះយាត្រា យាងយាសសីមា រំលងនៃយក្សនោះទៅ ។
២៨០. ប្រទះសួគ្រីពយំនៅ ហើយនាំព្រះទៅ នគរខាះខិនប្ញរី ។
២៨១. ផ្ទាំងមួយសួគ្រីពធិបតី តនិងពាលី ប្រយុទ្ធកណ្តាលវេហាស៍ ។
២៨២. ហើយឆ្លាក់ជាព្រះរាមា ថ្វៃងសរក្រុងពា លីលុះក៏ក្ស័យជីវិត ។
២៨៣. ផ្ទាំងមួយជាព្រះសីលា និងអស់ពលស្វា ចិតសិបអក្ខោភិនី ។
២៨៤. ស្តេចដាក់ប្របឆ្មេរនរទី ទៀបជើងគីរី នៃគន្ធមាទន៍បព៌ត ។
២៨៥. ផ្ទាំងមួយស្តែងស្តេចសន្ទត់ ត្រាសប្រើអង្គត ហនុមានមហិមា ។
២៨៦. ឲ្យទៅអញ្ជើញក្រុងមហា ជំពូរាជា គិតរិះជំនុំចងថ្នល់ ។
២៨៧. ផ្ទាំងមួយនោះឆ្លាក់អស់កល ធ្វើជាមណ្ឌល់ ប្រាសាទប្រសើរពិចិត្រ ។
២៨៨. ឆ្លាក់ជាហនុមានស្អួយស្នាក់ ទៃនទិព្យដ៏ពិចិត្រ សៃយាសន៍នៃមហាជំពូ ។
២៨៩. ហោះទាន់អង្គទនៅផ្លូវ អង្គតនិបទៅ នាស្វាហនុមានឯងនៃ ។
២៩០. ផ្ទាំងមួយនោះសោតឆ្លាក់ល្អក្រៃ ជាព្រះពន្ធាជ័យ សម្តេចព្រះរាមរាជា ។
២៩១. ផ្ទាំងមួយសោតធ្វើជា ស្តេចប្រែកាឡាជា ព្រះនរាយណ៍ស័ក្តិសាធ ។



២៩២. ឆ្លាក់ជាជម្លូវនធរនាថ ប្រណម្យក្រាបបាទ នរាយណ៍រាមាទេពថ្វៃ ។
២៩៣. ផ្ទាំងមួយជាព្រះជេស្ឋជៃ ស្តេចផ្តូកហឫទ័យ ស្រណោះទេពីសីតា ។
២៩៤. ស្តេចប្រើហនុមានមហិមា នាំព្រះសន្ធរា ទៅសួរព្រះរាជទេពី ។
២៩៥. ឆ្លាក់ជាហនុមានដ៏ក្របី ហោះដោយជលធី ក៏ទៅនគរលង្កា ។
២៩៦. ឆ្លាក់ជាឥន្ទ្រជិតមហិមា ថ្វៃងសរនាគា ក៏ចងហនុមានដឹមនោ ។
២៩៧. ឆ្លាក់ជាក្រុងរាពណ៍មោហា កំឡៅមុលហោ ពុំដឹងទឹងកើតអន្តរាយ ។
២៩៨. ចាញ់កលមាយាឧបាយ លុះលាញខ្ចាត់ខ្ចាយ វិនាសទាំងស្ថានមណ្ឌល់ ។
២៩៩. រីផ្ទាំងមួយឆ្លាក់អស់កល ធ្វើជាចងថ្នល់ កណ្តាលនៃមហាសមុទ្រ ។
៣០០. រីផ្ទាំងមួយសោតប្រាកដ្ឋ ឆ្លាក់ជាអង្គទ ក៏នាំទ្វូវសារព្រះនរាយណ៍ ។
៣០១. អង្គទជួបដល់បន្ទាយ យកដង្គត់វាតវាយ ក៏ធ្លាយបន្ទាយប្រាកដ ។
៣០២. ផ្ទាំងមួយឆ្លាក់ជាអង្គទ ពើបពះប្រយុទ្ធ និងភគណោសមហិមា ។
៣០៣. អង្គទសង្កត់សិរសា ផ្ទប់ផ្ទាល់ពសុធា ក៏យារព្រះខ័នបីសំពង ។
៣០៤. ហើយឆ្លាក់ផ្ទាំងមួយសោតហោង អង្គទទ្រើសឃ្នង ក៏ដល់សាលាប្រាកដ ។
៣០៥. ឆ្លាក់ជាអាមាត្យមួយរត់ មកអញ្ជើញអង្គទ ក៏តឿនប្រញាប់ទៅថ្វាត់ ។
៣០៦. ផ្ទាំងមួយឆ្លាក់ឆ្មៅពិចិត្រ ជាប្រាសាទរតន៍ ភិមានក្រុងរាពណ៍ប្រាកដ ។
៣០៧. ហើយឆ្លាក់ជាព្រះអង្គទ វិលវែងក់មកុដ អំពីព្រះសិររាពណា ។
៣០៨. ផ្ទេកផ្ទោះហោះលើវេហាស៍ ក្រុងរាពណ៍មហិមា ក៏ក្រោធពន្ទឹកប្រស្បក្ស ។
៣០៩. ហើយឆ្លាក់ជាសេនាយក្ស សិងនាយអង្គរក្ស ទាំងប្ញូនក៏ហៅហានក្លា ។
៣១០. ហោះតាមប្រយុទ្ធសោះសា អង្គទមហិមា ក៏ចាប់ទ្វូវជើងវាយវាត់ ។
៣១១. ឆ្លាក់ជាក្រុងរាពណ៍ខ្វាល់ក្តាត់ ឲ្យបើកឆ័ត្ររតន៍ ដៃហាំងស្រឡប់សុរិយា ។
៣១២. ផ្ទាំងមួយជាសួគ្រីពរាជា នាំអស់ពល់ស្វា ទៅកាច់រំលើងឆ័ត្រជ័យ ។
៣១៣. ឆ្លាក់ជាកុម្ភកាណ៌លើសក្រៃ ខាស់ខែងវិលវៃ ចាប់បានសួគ្រីពរាជា ។
៣១៤. នាំទៅថ្វាយក្រុងរាពណា ហនុមានមោះហិមា កាឡាផ្ទាប់នៅភ្លោងទ្វារ ។
៣១៥. ទោះត្រូវកុម្ភកាណ៌ជួលផ្ទារ សទ្ធប់នៅនា កណ្តាលប្រវាលប្រថពី ។
៣១៦. ឆ្លាក់ជារាពណាធិបតី ឲ្យទូងភេរី ប្រាប់អស់មន្ត្រីយោធា ។

៣១៧. ធ្លាក់រូបពិភេកអនុជា គន់គួរហោរាចារ សំដែងនូវក្បួនសាស្រ្តសៃ ។
៣១៨. ធ្លាក់ជាក្រុងរាពណ៍ខ្វាល់ក្រៃ កាយករគាងដៃ បណ្តេញពិភេកអនុជជា ។
៣១៩. ផ្ទាំងមួយនោះសោតហោងណា លោកធ្លាក់ផ្ទៅជា ពិភេករត់ចូលទ័ពជ័យ ។
៣២០. ធ្លាក់ជាព្រះរាមទេពថ្លៃ ទ្រង់ករុណាក្រៃ ទទួលពិភេកហោរា ។
៣២១. ផ្ទាំងមួយធ្លាក់ជារាពណា ត្រាសប្រើយក្សា នូវរក្សសេនាចេញចរ ។
៣២២. ចូលចាំព្រៃព្រឹក្សាករ ចាំក្វាត់ពានរ គឺបោកបាក់សេនា ។
៣២៣. ផ្ទាំងមួយសោតធ្លាក់ជាមហា រោក្ខរក្សមហិមា ប្រយុទ្ធនូវរក្សសៃនខ្វំ ។
៣២៤. ឯពលយក្សសៃនទីករ ពះពលពានរ ប្រាំម៉ឺនប្រយុទ្ធខែងខំ ។
៣២៥. ដកដើមព្រឹក្សាដាលធំ ខ្វះស្ទុះស្ទួយភ្នំ ប្រហោកប្រហែកភ្លើងច្រាល ។
៣២៦. ពានររុករានដេញដាល់ ស្ទុតស្លាប់ក្រាសក្រាល រង្គាត់រង្គាលទាំងព្រៃ ។
៣២៧. ធ្លាក់ជាក្រុងរាពណ៍អរក្រៃ ទះករគាងដៃ ក៏ទ្រង់អំពរភូសា ។
៣២៨. ផ្ទាំងមួយក្រុងរាពណ៍មហិមា បើកឆ័ត្រជ័យា ចាំងឲ្យងងឹតពានរ ។
៣២៩. ធ្លាក់ជាព្រះរាមថ្លៃងសរ អប្ញទ្ធិចន្ទបវរ រំលាងរំលំឆ័ត្រជ័យ ។
៣៣០. ផ្ទាំងមួយក្រុងរាពណ៍ក្រោធក្រៃ ប្រើអាមាត្យនៃ អញ្ជើញកុម្ភកាណ៌មកណា ។
៣៣១. ផ្ទាំងមួយកុម្ភកាណ៌រាជា លើកទ័ពលីលា ព្រះរាមស្តេចយល់អស្ចារ្យ ។
៣៣២. ផ្ទាំងមួយធ្លាក់ជាកុម្ភកាណ៌ ធាត់ធំសាម្មា ប្រយុទ្ធនិងព្រះលក្ស ។
៣៣៣. ព្រះលក្សថ្លៃងសរក៏ផ្ទា ផ្តួលកុម្ភកាណ៌ ក៏លុះអំណាចព្រះអង្គ ។
៣៣៤. ផ្ទាំងមួយឥន្ទ្រជិតដោមយង់ ថ្លៃងសរចាញ់បង់ ស្ទួរពាន់ក៏ជានាគា ។
៣៣៥. ព័ន្ធពាក់ព្រះលក្សអនុជា នូវអស់ពលស្វា ក្រញោនៗទីទៃ ។
៣៣៦. ផ្ទាំងមួយព្រះរាមខ្វាល់ក្រៃ កាច់កៅទណ្ឌជ័យ នឹងពោះឲ្យផេះស្ទួគាំ ។
៣៣៧. ធ្លាក់ជាគ្រុឌរាជមហិមា ហិចហោះមកណា ក៏នាគនោះរត់ខ្វាត់ខ្វាយ ។
៣៣៨. ផ្ទាំងមួយព្រះលក្សពរនាយ ទ្រើសទ្រង់ឫទ្ធីសាយ ក៏ទ្រង់កៅទណ្ឌសរថ្វា ។
៣៣៩. ផ្តួលឥន្ទ្រជិតយក្សា កណ្តាលពសុធា វិនាសទាំងពលយក្សយង់ ។
៣៤០. ផ្ទាំងមួយសោតធ្លាក់ជាក្រុង រាពណ៍ក្រោធបទបង់ ព្រះរាជបុត្រច្បងណា ។
៣៤១. ទសមុខសៃនសោយសោកា ករកាន់ខ័នថ្វា ក៏ហួតមហាគ្រឺ ។



៣៤២. យក្សកាន់សិរសាក្សត្រី សីតាទេវី ប៉ុនប៉ងពិឃាដឲ្យមរណ៍ ។
៣៤៣. ផ្ទាំងមួយធ្លាក់ជាមហាសរ លើកពលចេញចរ ប្រយុទ្ធនូវអង្គទនា ។
៣៤៤. អង្គទករកាន់ខ័នថ្វា ផ្ទាញមហាសរណា ក៏លាញវិនាសអន្តរាយ ។
៣៤៥. ធ្លាក់ជាក្រុងមហាអត្តិកាយ នូវព្រះលក្សពណ្ណរាយ ក៏តប្រយុទ្ធនូវគ្នា ។
៣៤៦. ព្រះលក្សទ្រង់សរផ្ទាញផ្ទា ផ្តួលអត្តិកាយមហា យក្សានូវពលណាស់នៃ ។
៣៤៧. ផ្ទាំងមួយធ្លាក់ជាត្រីសិរ លើកពលមកមីរ សំញើញសំញែងរឿងរុង ។
៣៤៨. ធ្លាក់ជាព្រះរាមស្តេចគង់ កៅទណ្ឌបីតម្រង់ ប៉ុនប៉ងទទួលយក្សា ។
៣៤៩. ធ្លាក់ជាពិភេកហោរា បង្គំរាជា សូមឃាត់ព្រះរាមស្តេចឈប់ ។
៣៥០. ផ្ទាំងមួយធ្លាក់ជាឱសុភ ហនុមានប្រតិរុទ្ធ ប្រយុទ្ធនូវត្រីសិរណា ។
៣៥១. ត្រីសិរថ្លៃងសរសក្តិផ្ទា ហនុមានមហិមា ឱសុភក៏ស្ទុះចូលចាប់ ។
៣៥២. បានកៅទណ្ឌទាញបី ក្រលាប់វិលវែផៀងឆាប់ សម្លាប់អសុរៈត្រីមុខ ។
៣៥៣. ផ្ទាំងមួយធ្លាក់ជាវិនគុត្ត លើកពលតគ្រុក ករកាន់កៅទណ្ឌសរថ្វា ។
៣៥៤. ធ្លាក់ជាពិភេកសេនា ករកាន់ខ័នថ្វា ទទួលប្រយុទ្ធរឿងរុង ។
៣៥៥. ពិភេកស្ទុះស្ទែងដ័ត្រនង់ ពះអង្គនូវអង្គ ក៏ដួលនូវវាលមរណា ។
៣៥៦. ផ្ទាំងមួយធ្លាក់ជាមហា ក្បាលធំមហិមា ក្រទាករកាន់ដំបង ។
៣៥៧. ឱសុភសេនាទ្រើសឃ្នង កាន់ខ័នបីសំពង ក៏ពះប្រយុទ្ធមហិមា ។
៣៥៨. ពាក់ពន្ធប្រវ៉ណ្ឌផងគ្នា ឱសភមហិមា ក្រទាក៏ផ្តួលមហាក្បាល ។
៣៥៩. ផ្ទាំងមួយជាទសមុខមារ មមីជាប់ជាល់ ករកាន់ដំបងផ្ទារង ។
៣៦០. ធ្លាក់ជាក្របិន្ទកេសរ កាន់ខ័នចេញចរ ទទួលប្រយុទ្ធសោះសារ ។
៣៦១. ក្របិន្ទកេសរមហិមា ផ្តួលទសមុខណា វិនាសទាំងពលយក្សយស ។
៣៦២. ផ្ទាំងមួយជាមុខរាក្ខខាស លើកពលក្រៃក្រាស ករកាន់ដំបងបង្វិល ។
៣៦៣. ធ្លាក់ជារូបមហាខុន្ទិល ករកាន់ដំបងពេជ្រមនី ប្រយុទ្ធនូវមុខរាក្ខា ។
៣៦៤. ខុន្ទិលវើលខែងខា ផ្តួលមុខរាក្ខា ក៏លុះក្សិណក្ស័យមរណា ។
៣៦៥. ផ្ទាំងមួយធ្លាក់កុម្ភណ្ឌក្រទា សរឯងមហិមា ករកាន់ដំបងគួរស្ញែង ។

៣៦៦. ធ្លាក់ជាឧន្ទិលជាញជែង កាន់ដំបងខាះខែង ទទួលប្រយុទ្ធយក្ស ។
៣៦៧. ឧន្ទិលរឹងមុខមហិមា ផ្តួលកុម្ភៈក្រទា ផារវិនាសក្សិណក្ស័យ ។
៣៦៨. ផ្ទាំងមួយសោតធ្លាក់ជាខែ មោលច័ក្រលើសក្រៃ ករកាន់ដំបងគ្រវី ។
៣៦៩. ធ្លាក់ជារូបកាំពាលី កាន់ខ័នជ័យស្រី ទទួលប្រយុទ្ធយក្ស ។
៣៧០. សរពាលីឫទ្ធីមហិមា មុតមហាយក្ស វិនាសសាបសូន្យអស់ហើយ ។
៣៧១. ទសមុខមារឯងឥតត្រើយ ឥតពុំនាក់ឡើយ វិនាសសូន្យសោះដ៏អសារ ។
៣៧២. រំពឹងទន្ទឹងពលមារ ពីក្រៅចក្កវាឡ ក្រោមបាទសុមេរុនាយណា ។
៣៧៣. ផ្ទាំងមួយជាព្រះរាមា ស្តេចមានចេស្តា ឫទ្ធីបារបីសោតសម ។
៣៧៤. ស្តេចគង់លើសុគ្រីពឧត្តម ហោះស្ទុះស្ទួយភ្នំ ពន្លឺកន្លូវឫទ្ធីប្រាកដ ។
៣៧៥. ធ្លាក់ជារាពណ៍គង់រាជរថ ទឹមសឹង្ហប្រែព្រត ប្រយុទ្ធនិងព្រះនរបតី ។
៣៧៦. ហោះផ្សងកណ្តាលទុភី សេនាសេនី អនេកអសុរដ៏ទាហាន ។
៣៧៧. សេនាសោតសឹងតែមាន ជំនិះសព្វប្រាណ ដោយអង្គអសុរដ៏សនី ។
៣៧៨. ខ្វះជិះសឹង្ហសារាជសីហ៍ ជិះគោដំរី ជិះតោរមាសមហឹង្សា ។
៣៧៩. ជិះគោមៀងមីសកា លៀងភាដំរ៉ា បារមាំងប្រើសទ្រាយសី ។
៣៨០. ជិះគុជជិះលាពាជី ជិះហង្សឥន្ទ្រី ជិះខ្វារមាសភ្លើងប្រាល ។
៣៨១. ជិះសិង្ហនាគទ្វូវនាដ្ឋនា ជិះជុំកាភារ កែលីនទ្វូវឱ្យនមន្តរ ។
៣៨២. ជិះខ្ទឹងនិភាសអ្វផ្ជជិះសរ វង្កាទ្វូវម្ករ ទ្វូវមៀមពាក់ព្រៃចរណី ។
៣៨៣. ខ្វះជិះសទ្ទត់កាកី មាំងសាំងរាជសីហ៍ ភិមឡៃទ្វូវត៊ីសិង្ហា ។
៣៨៤. ខ្វះជិះកម្រាំងកលាំ ខ្វះជិះចាមរា ប្រដាប់ជំនិះគ្រប់ប្រាណ ។
៣៨៥. ខ្វះជិះអគ្គិយលវន្ទ អង្គអគ្គិយស្បាន់ គីសិង្ហទ្វូវស្មានដ៏ប្រាកដ ។
៣៨៦. ខ្វះជិះខ្វាទីមរាជរថ មកឆ្វាយដ៏ប្រាកដ អនេកអាសុរកាឡា ។
៣៨៧. ស្មើញស្មេញញើញញេញទន្តា ចង្កូមផ្ងាញផ្ងា ប្រទើសប្រទែងច្រូងច្រាង ។
៣៨៨. ប្រៀវប្រែតបរបទវីវាង ក្រាយក៏អយតអាង សម្ងែញសម្ញើមដ៏ពន្លឹក ។
៣៨៩. ពលស្វាមហិមាឥតភ្ញឹក ចរចូលចាប់ចឹក យក្សាកន្ត្រាក់កាន់ខ្លាប់ ។
៣៩០. យក្សយសខែងខាស់ចាប់កាប់ ស្វាប្រែក្រឡាប់ ចម្បាប់ដណ្តើមអាវុធ ។



៣៩១. ពានររហ័សពេកក្តាត់ សិងគង់នីរពាត់ ពុំចុតពុំទ្រុតដល់មួយ ។
៣៩២. យក្សសោតខាះខែងខំជួយ យក្សៗស្វាមួយ ជ្រោមញ្រួតប្រចាប់សោះសារ ។
៣៩៣. ពានរវិលវែមហិមា ជើងជាន់យក្សា មួយនោះសង្កត់ពាល់ដី ។
៣៩៤. ដៃពីរចាប់ចិកសិរសី យក្សមួយលើកលី គ្រវាសគ្រវីបោកខ្វាត់ ។
៣៩៥. ចោលចុះយក្សដួលញញមាត់ ជើងធាក់យក្សខ្វាត់ ក៏ដួលទាំងពីរស្លាប់ស្ងឹង ។
៣៩៦. យក្សខ្វះករកាន់លំពែង ស្វាចាប់សំញៀញ គ្រវីគ្រវាសយក្សដួល ។
៣៩៧. ស្វាខ្វះចាប់ជើងយក្សយួរ ខ្វះចាប់កម្ទួល ជ្រមិនជ្រមុជជាន់ឈ្លី ។
៣៩៨. ស្វាខ្វះចាប់ចឹកសិរសី បង្កត់ហើយឈ្លី គ្រវីកកេរខាំក្បាល ។
៣៩៩. ស្វាខ្វះពារពោះខាំថ្កាល់ ស្វាខ្វះមាក់ងារ ក៏ខាំនៃផ្ទឹងជំនី ។
៤០០. ខាំមុខមាត់ពាក់ជើងពីរ ខ្វះខាំកកេរ ដើមភ្លៅសន្ធាក់សរសៃ ។
៤០១. ស្វាខ្វះខាំជើងខាំដៃ ស្វាខ្វះខាំផ្ទៃ គ្រញីគ្រញៀងមិកម្ទួល ។
៤០២. ស្វាខ្វះស្ទុះស្ទះចាប់ផ្តួល ខាំដងបង្ករ យក្សាស្រទាងស្ទុតស្លាប់ ។
៤០៣. យក្សខ្វះក្រចៅចូលចាប់ ស្វាប្រែក្រឡាប់ ចម្បាប់បោកយក្សសន្ទប់ ។
៤០៤. ស្វាខ្វះផុសដៀងដាល់តប់ ខ្វះប្រាទប្រតប់ ប្រទះប្រពានដ៏ប្រពាក់ ។
៤០៥. ខ្វះចាប់កាន់កៀរករយក្ស ខ្វះឆក់កន្ត្រាក់ ដៃយក្សបំបាក់សោះសា ។
៤០៦. យក្សខ្វះបាក់ខ្នងបាក់ស្វា ស្ទុតស្លាប់លើគ្នា គណនាពុំបានឡើយហោង ។
៤០៧. ស្វាខ្វះកាន់ខ័នបីសំពង ខ្វះកាន់ទ្វូវដំបង គ្រវែងគ្រវាសដ៏គ្រវី ។
៤០៨. ស្វាខ្វះចូលចាប់សឹង្ហស៊ី ខ្វះចាប់គោមី ចាប់តោរមាសលៀងផ្ទៃ ។
៤០៩. ខ្វះចាប់មាំងសាំងរាជសីហ៍ ខ្វះចាប់ដំរី ជញ្ជៀងប្រភើចមហិមា ។
៤១០. ស្វាខ្វះដៃនិបចាប់លា ស្វាខ្វះចាប់ខ្វា ក៏ពានកកេរឃ្លួយយាស់ ។
៤១១. ខ្វះហែកទាញទង់បន្ទះ ដោយតេជតបះ សង្កត់សង្កិនញាំញី ។
៤១២. បែនបុកច្របាច់កិតឈ្លី ជាន់ផ្លាប់ផ្លាល់ដី គ្រវីគ្រវែងឥតប្រមាណ ។
៤១៣. ខ្វះកាច់រាជរថអស្សយាន ខ្វះស្ទុះឡើងពាន លើរាជរថដ៏លលាម ។
៤១៤. ខ្វះយកជើងជាន់កង់កាំ ខ្វះសោតលោតខាំ កង់កាំក៏បាក់ដំបទ ។
៤១៥. ខ្វះស្ទុះភើចយក្សដ៏ប្រាកដ ធ្លាក់ពីរាជរថ ប្រយុទ្ធប្រចាប់ផងគ្នា ។

៤១៦. អសុរធាត់ធំក្រទា រឹងរូសហានក្លា ប្រយុទ្ធប្រយ័ត្តទ្ទូវកម្លាំង ។
៤១៧. ខ្វះខែងជាញដែងរូសរាំង ប្រក្ខួតប្រណាំង ប្រទះប្រទូសវិលវៃ ។
៤១៨. ពលស្វាមហិមានិរភ័យ សឹងហ៊ឹកហ៊ឹនដៃ មនោមាទះឫទ្ធីផង ។
៤១៩. ចាប់ដីរគុជសីទ្ទូវសឹង្ហ កាងករដ៏សន្ទឹង ក៏រឹងឆក់ឆ្វលបាទា ។
៤២០. ចាប់ចោលទៅលើយក្សា បាក់កបាក់ស្មា បាក់ខ្នងបាក់ជើងបាក់ដៃ ។
៤២១. កម្មុខខ្វាត់ទៅទីទៃ ស្ទុតស្វាប់ពេកក្រៃ រងោករងោលរគៃល ។
៤២២. ខ្វះដួលផ្ទុះធ្វាយពោះទ្រេល រនាប់រណែល ប្រព័ទ្ធប្រពាក់លើគ្នា ។
៤២៣. យក្សខ្វះខែងខះមហិមា ស្វាស្ទុះបីក្រទា ប្រជ្ជួបប្រចាប់ចុងដៃ ។
៤២៤. ស្វាសោតក្រេវក្រោធជាញជ័យ ខាះខែងវិលវៃ លោតចាប់ពានលើយល់ផ្តើង។
៤២៥. ខ្វះពានព័ទ្ធជើងនិងជើង ដៃសោតប្រឹងឡើង ប្រចាប់ប្រកាប់និព្វរតន៍ ។
៤២៦. ប្រចាប់ដណ្តើមអាវុធ ឆក់ឆាប់វៃស្ទាត់ ក្រឡេកក្រឡាប់គ្រវី ។
៤២៧. ស្វាខ្វះចូលចាប់ដីរ សង្កត់ហើយឈ្វី បង្វិលសម្រុញសម្រុក ។
៤២៨. ស្វាខ្វះពារពះឈមមុខ ទុងទាញដកភ្ញុក បង្កត់ដីរដួលទ្រោម ។
៤២៩. ពះយក្សប្រយុទ្ធទ្រលោម ចម្បាំងចំណោម អធិកពន្ទឹកមហិមា ។
៤៣០. អស់សេនាពលពានរា ស្វារស្ទុះចាប់សរ អាវុធអសុរសេនា ។
៤៣១. ចាប់បានកិនកាច់សោះសារ គ្រប់អស់ទាំងស្វា ចម្បាំងទ័ពស្រួចក្រាស់ក្រៃ ។
៤៣២. ស្វាខ្វះករកាន់ទង់ជ័យ ខ្វះខ្វាំងវិលវៃ ផ្ទេកផ្ទោះក៏ហោះត្រដួច ។
៤៣៣. ក្រសោបចាប់សរកាច់ក្ទួច ពុំឲ្យលែងរួច ប្រជួចខាំកាច់និងមាត់ ។
៤៣៤. យក្សានិងស្វាសឹងស្ទាត់ ប្រយុទ្ធប្រយ័ត្ត ប្រចាក់ប្រកាប់ច្រើនក្រៃ ។
៤៣៥. ហាក់ដូចរូបរស់វិស័យ ក្សរក្សាច់ដ៏ប្រពៃ ចម្លាក់ចម្លៀវចនា ។

## នេះបទភាគគតិ

៤៣៦. ផ្ទាំងមួយសោតនៃ ធ្លាក់ជាព្រឹក្សព្រៃ បពិតគុហា និត្យនៅនាស្ថាន
ហិមពាន្តនាយណា ជាស្ថានព្រះមហា ឥសីឯងនៃ ។



៤៣៧. ឫសីនោះណា ទ្រើសទ្រង់នាមា ព្រះក្រិស្សថ្វាថ្លៃ មានឫទ្ធិតេជះ
តបះក្រាសក្រៃ ស្ទឹងស្មាតនោះនៃ សូត្រសិល្ប៍ស្វាធ្យាយ ។
៤៣៨. រឹងឫទ្ធិចេស្តា លើសលែងអស់មហា ឫសីសម្លាយ ឫសីគ្រូញក្រាប
ដរាបសព្វសាយ សោតសឹងខ្វល់ខ្វាយ ចូលមកវន្ទា ។
៤៣៩. ផ្ទាំងមួយប្រាកដ ធ្លាក់ជាបពិត សុមេរុឯងណា ធ្លាក់ជាភិមាន
ស្ថានត្រៃត្រឹង្សា ធ្លាក់ជាចូឡា មុណីថ្វាថ្លៃ ។
៤៤០. ហើយលោកធ្លាក់ជា ស្វគ៌ចតុមហា រាជិកាប្រពៃ ភ្នំយុគន្ធរ
ភ្នំករវីកនៃ ឥសន្ធរឮ សុទស្សន៍សោភ័ន្ត ។
៤៤១. ភ្នំនិមិន្ធរ វិនតកប្បវរ ភ្នំអស្សកណ្ណ រវៀសរវណ្ណ
ភ្នំសត្តបរិភ័ណ្ឌ សមុទ្រសឹងខ័ណ្ឌ ជ្រោះជ្រៅមហិមា ។
៤៤២. ហើយធ្លាក់ជាភ្នំ ត្រីកូតបន្សំ រងចាធារមហា សុមេរុបពិត
ប្រាកដក្តាត់ណា ហើយលោកធ្លាក់ជា ស្ថានអសុរភព ។
៤៤៣. ហើយលោកធ្លាក់ជា ស្ថានកំពែងមហា នរកឧសុភ បរិវារមួយៗ
ប្រាំបួនដណ្តប់ នរកធំគម្រប់ សាមសិបស្ថានណា ។
៤៤៤. នរកលើនោះ ដោយនាមហៅឈ្មោះ ហៅសញ្ជិតមហា នរកក្រោមនោះ
សោតឈ្មោះនាមា ហៅកាលសូត្រមហា នរកនាយនៃ ។
៤៤៥. អណ្តាប់នោះណា ហៅសង្ឃាដមហា នរកក្រក្រៃ អណ្តាប់នោះទៅ
ហៅរោរពនៃ មួយនោះនាមហៅ មហារោរពហោង ។
៤៤៦. មួយនោះអាក្រក់ ហៅជាប់នរក វិបាកកន្ទង មួយហៅមហាជាប់
ដ៏ភាបរូបរង វិបាកក្តាត់ហោង ពន្ទឹកអស់ក្តី ។
៤៤៧. នរកមួយនោះ ដោយនាមហៅឈ្មោះ មហាអវិចី មើលមុខគួរខ្វាច
ពុំអាចស្រដី ស្ថានទាំងប្រាំបី ជុំពួកនោះណា ។
៤៤៨. នរកឧសុភ ប្រាំមួយដណ្តប់ បរិវារផងនៃ នរកធំៗ
បួកផ្សំផងគ្នា អស់ទាំងនោះណា មួយរយសែសិបបួន ។
៤៤៩. សឹងជាកំពែង ធ្នូកធ្លាស់ខ្វាត់ខ្វែង ថ្នល់ថ្នាក់ថៃធ្នូន គ្រាំសឹងមូតល្អក់

អាក្រក់អស់ខ្លួន នរកពីងពួន ច្រាសច្រាលសឹងភ្លើង ។
៤៥០. ផុរឆេះឆ្វរឆាប់ នរកស្ទួតស្លាប់ ក្សិណហើយកើតឡើង បន្ទាផ្តៅវាស
ពេញពាសជាប់ជើង ក្រាសក្រែសឹងភ្លើង រលាកអាត្មា ។
៤៥១. បក្សីត្មាតក្អែក ចរចិកហួហែក ជញ្ជែញភោក្តា ស្លាប់ហើយរស់វិញ
អម្ពេញឈឺផ្សា ផ្លែត្លួតពះពារ ប្រកាប់ឆក់ធី ។
៤៥២. នរកខ្លះសោត យមភ្ជូបាលក្រេវក្រោធ ចាប់ចិកសិរសី ឆ្លួលឆាំងវាយវាត់
ចាក់កាប់គ្រវី ដួលដេកដល់ដី ដែកជុំច្រូញច្រាល ។
៤៥៣. ផុរឆេះជាភ្លើង ភោរភាវលេចឡើង បម្រាស់ផ្តាប់ផ្ងារ កាលមុនហេតុចិត្ត
ពុំគិតធ្ងន់ស្រាល ឆោតផុកបណ្តាល ដុតសត្វទាំងរស់ ។
៤៥៤. នរកមួយនោះនៃ ចុងជើងចុងដៃ ដុតអណ្តាតណា ដាក់ច្រួលច្រវាក់
អន្ទាក់ភ្ជួនា ទ្រុងដែកសោះសារ ដាសមាត់ទោះផង ។
៤៥៥. នរកមួយណា ពោះធំមហិមា អាក្រក់កន្ទង់ ជាប្រេតតិរច្ឆាន
សាមាន្យពេកហោង មួយនោះសោតចង សក់ខ្ចាប់និងគ្នា ។
៤៥៦. នរកមួយនោះនៃ ចងជើងចងដៃ ផ្ទាប់ដើមព្រឹក្សា ខ្លះនៅឯក្នុង
ខ្លះឡើងរកា ដែកដើមមហិមា សឹងឆេះជាភ្លើង ។
៤៥៧. អ្នកខ្លះចងរោល ខ្លះឡើងខ្លះចោល ខ្លះយកក្បាលចុះ ព្រេចនិងដីរ
ខ្វាទំពារពោះ ភើចពាំហែកពោះ យកហែកខាំស៊ី ។
៤៥៨. ឯនរកផង ច្រើនពណ៌កន្ទង អនេកជាស់ដេរ ស្រដីពុំយល់
ពុំស្គាល់ឡើយហោង ទោះប្រុសស្រីផង សឹងមានគ្រប់អង្គ ។
៤៥៩. ផ្ទាំងមួយនោះណា ព្រះកេតុមាលា មានបុណ្យកន្ទង គង់លើក្រឡា
សម្តេចឯងហោង ស្តេចមួយរយផង ក្រាបថ្វាយបង្គំ ។
៤៦០. សឹងលាទៅស្រុក រៀបមន្ត្រីមុខ អនេកថ្កើងថ្កុំ ដោយយសសម្បត្តិ
មហាក្សត្រិយ៍ឧត្តម ទីទៃតូចធំ ថ្កើងក្រៃមហិមា ។
៤៦១. សឹងជិះគុជសា ធាធំនិទា ហៅហ៊ានមោះសា មើលអស់រេហ៍ពល
សកលយោធា កាន់គ្រឿងគ្រប់គ្នា ខែលដាវលំពែង ។



៤៦២. ខ្លះពាក់មួកស្បែក ខ្លះពាក់មួកដែក មាត់ស្វាសំញែង ខ្លះកាន់សេលា
ធ្នូទ្ធនដងវែង ខ្លះកាន់លំពែង ត្រីមុខៗពីរ ។
៤៦៣. សឹងពាក់ក្រោះក្រាស់ កាន់គ្រឿងសហស្ស អាវុធមុតថ្វា កាន់គ្រឿងអាវុធ
ប្រកិតដាសដេរ មុខមាត់មមីរ មម្វរសោះសា ។
៤៦៤. មើលឯអភិរម្យ ទង់ជ័យល្បុំ ភ្ជិងភ្ជស់ឆាយា បើកបាំងក្សត្រិយ៍ថ្ងៃ
ដោយព្រៃព្រឹក្សា ជិះសេះជិះលា ហែរៗនាំមុខ ។
៤៦៥. តន្ត្រីត្រែស័ង្ខ ភេរីរគាំង ពាទ្យគងហ្វ៊ូទុក ស្រឡៃសំភោ
ពិណពេទ្យឮផុក ពលជើងគគុក គគឹកមហិមា ។
៤៦៦. ស្តេចខ្លះទ្រង់ផ្តាក់ ខ្លះស្តាយប្រទាក់ ព្រះខ័នមុតថ្វា ខ្លះទ្រង់កៅទណ្ឌ
លំពែងជ័យា កងរុងរំជា ខែលជ័យល្អថ្កើង ។
៤៦៧. លើកទ័ពចេញទៅ មុះមុខសំដៅ តឿនពលរួសឡើង ពលរត់សស្រាក់
ដោយទ័ពរុងរឿង ស្នូរស័ព្ទថ្កុំថ្កើង ដោយស័ព្ទមនុស្ស ។
៤៦៨. វីរអស់ក្សត្រី ជារាជទេពី ស្តេចផងនោះណា សឹងពាក់ទឹកមាស
ដាសជារចនា ប្រដាប់ថ្ងៃថ្វា ល្អៗទីទៃ ។
៤៦៩. នរនាថនារី ស្រស់ស្រេចប្រិមប្រិយ សក្តិសមប្រពៃ ហែរៗទេពី
ក្សត្រីថ្វាថ្ងៃ តាមដោយទ័ពជ័យ ថ្កុំថ្កើងអាត្មា ។
៤៧០. ផ្តោះទៅនគរ បូរីបវរ ខែត្រខ័ណ្ឌសេមា ដោយទីដោយទិស
លំនៅអាត្មា ក្សេមក្សាន្តទ័យា វិបូណ៌សព្វសាយ ។
៤៧១. វីផ្ទាំងឯលិច នោះសោតសិងស្តេច ហៅបរិពារបញ្ឈប់ ច្បាំងនិងទូភី
ហៅសត្វគម្រប់ នោះឯងសោតសព្វ ក្រោយមុខសោតណា ។

**នេះបទពំនោល**

៤៧២. កាល្ពោះវិស្ណុការនោះនៃ តាក់តែងឆាប់ក្រៃ ករកាន់សឹងការឃ្មីឃ្មាត ។
៤៧៣. ជាងមួយធ្វើជាប្រាសាទ ប្រសើរស្អាងស្អាត កុំនៅកុំនាប់បីប្រពៃ ។
៤៧៤. ទាំងប្រាំព្រោងព្រាយថ្វាថ្ងៃ សិងមានតម្លៃ ពិចិត្រឆ្វរចរេក្ខា ។

៤៧៥. ប្រាសាទនិមួយសោតណា មានទ្វារចេញជា ប្រាំពីលៗជាន់ជុំ ។

៤៧៦. ចតុរសនៃសសរស្តម្ភ មាលមាសទែងទុំ ក៏ទ្រង់ប្រាំពីរជាន់ជិត ។

៤៧៧. សសរទ្រូងមួយមានពណ៌ ឆ្លាក់ជាភ្ញីវារ គ្របកប្ញទមដីបវរ ។

៤៧៨. រចនាជារូបម្ករ គ្រប់ជ្រុងសសរ ក៏ពាន់ក៏ពាំភ្ញីមាស ។

៤៧៩. ក្នុងក្អក់កញ្ចក់ពេញពាស តាមដោយផ្តែរផ្ទាស រំលេចរំលង់ឆ្នុះឆ្មៅ ។

៤៨០. ប្រាសប្រាលបីរទ្វាលល្ពៅ មាលមាសផ្តិនផ្តៅ ត្រចង់ត្រចះឆើតឆាយ ។

៤៨១. គ្របកប្ញទមរីករាយ រៀងរាល់សព្វសាយ ប្រពាក់ប្រព័ន្ធទងភ្ញី ។

៤៨២. ក្តារបែនត្រែទែនមាសថ្មី ឆ្លាក់ជាទងភ្ញី ជាគ្រុឌចូលចាប់នាគា ។

៤៨៣. ហោះទ្រត្រែទែនសុវណ្ណ កែកាងហត្ថា ក្រអើតក្រអួនស្នេហ៍ស្និទ្ធ ។

៤៨៤. រូបនាគហើយហាក់កំណើត រូបរស់បង្កើត ក៏ពានទ្វាជើងគ្រុឌគ្រប់ ។

៤៨៥. បង្ហួចបង្អួមរតន៍រៀង សាយសព្វជើងទៀន បបរបស់រាល់រាយ ។

៤៨៦. ដោយទ្វារប្រាសាទសព្វសាយ ជាងជាអស្ចារ្យ ក៏ចាប់ទ្វាទងភ្ញីវារ ។

៤៨៧. គ្រប់ជ្រុងប្រាសាទរតន៍រាស ឆ្លាក់ច្រើនពណ៌ណាស់ ដំរេកដំរាស់ភព្វផង ។

៤៨៨. រូបរាជសីហោះផ្សង ចាប់អម្រឹតឃ្នង សំដែងទ្វាតេជចេស្តា ។

៤៨៩. កេសររាជសីហ៍សោតណា ចេញពីគុហា រកចាប់ទ្វាគជាផង ។

៤៩០. រូបគ្រុឌចាប់ឆ័ត្រហោះផ្សង អស់សារពើផង អនេកអនន្តរគណនា ។

៤៩១. រូបហង្សចុះចាប់បុប្ផ ទំទៀបទិមត្ថា ប្រចិកប្រចាប់ទងភ្ញី ។

៤៩២. គ្របកប្ញទមរីកថ្មី រូបសត្វបក្សី ក៏សៀរស្លួរទំភ្ញីទង ។

៤៩៣. រូបសេកសារិកាសោតហោង ទំទីមផ្ទៀងផ្លង ក៏ចិកនៃកេសរផ្កា ។

៤៩៤. រីរូបបក្សីផងណា ច្រើនពណ៌ភាសា ខ្លះហើរខ្លះទំលោតលេង ។

៤៩៥. សាយសព្វប្រាសាទធំធេង ជាងជៅសឹងឈ្វេង ប្រដាប់រចនាពិពណ៌ ។

៤៩៦. មុខដាច់ប្រក់លើយានរាជ ហង្សកែមកាលម្ករ ក៏ពាំរតន៍ក៏ភ្ញីមាស ។

៤៩៧. ស្រកីស្រកាស្រស់ស្រេច ភ្ញីវារលាយលេច គ្របកប្ញទមរីករាយ ។

៤៩៨. ត្រីស្លូល៍កំពូលគាងឃ្វាយ មាសមែឆោមឆាយ ត្រដែតត្រដឹមដោមដួច ។

៤៩៩. កំពូលកំពស់ស្រោងស្រួច ក្នុងក្អក់រាល់រួច កុំនើងកុំនួចទីកទាល់ ។



៥០០. រូបទេពប្រណម្យរៀងរួច ករកាន់ករតួច ពិពណ៌បុប្ផផងគ្រប់ ។

៥០១. ជ្រុងសារពើរស្ងួតសាយសព្វ ទាំងប្រាសាទគ្រប់ សឹងរូបស្រីទេពអប្សរ ។

៥០២. កាន់ផ្កាឈ្វកមាសដ៏បវរ ទ្រង់ពស្ត្រាពរ ក៏ឈរគ្រប់រូបរតន៍រាល់ ។

៥០៣. រានហាលគ្រប់ទ្វាររុងផ្ទារ រៀងរួចទៅទាល់ កំពូលកំពែងក្រោមក្រែ ។

៥០៤. ភ្ជាក់ជ្រៃរូបនាគសន្ធឹង សងខាងឆ្វេងស្តាំ ឯក្បាលក៏លើកពពារ ។

៥០៥. រចនាផ្ទៀងផ្ទងសោះសា ដោយនៅមាត់ទ្វារ ប្រាសាទប្រសើរមហិមា ។

៥០៦. កិន្នរហង្សព្រហ៊ា កែសែនលៀងភារ ក៏ឈរជាជួររៀងរាយ ។

៥០៧. ប្រែប្រឹងបីសន្ធឹងគេរកាយ មៀងមើលសព្វសាយ ប្រយោជន៍ប្រយ័ត្នគ្រប់គ្នា ។

៥០៨. ទិមទែងមាសមែបិណ្ឌា រុងរឿងច្រាសច្រាល ចម្លាក់ចម្លៅស្រស់ស្រេច។

៥០៩. ច្រូងច្រាងរុងរឿងក្បូរក្បាច់ រូបរាងស្រស់ស្រេច រំលេចនៅក្បាច់ផ្តិនផ្តៅ ។

៥១០. មានរូបនោះសោតល្ពេញល្ពៅ សព្វដោយលំនៅ ឥតខ្វះចន្លោះឡើយណា ។

៥១១. អម្រឹតមាសមែចាំនៅ សាយសព្វទ្វារក្រៅ រហើតរហង់រាល់រាយ ។

៥១២. ល្អៗបីត្រចះឆើតឆាយ ផ្តិនផ្តៅព្រោងព្រាយ ពិចិត្រទ្វារតន៍រេខា ។

៥១៣. ហាក់ដូចភិមានឥន្ទ្រា ចុះចាកសួគ៌ា ក៏ស្រុតមកនៅផែនដី ។

៥១៤. ជាងមួយប្រដាប់ខ្មាន់ខ្មី ជារូបបក្សី នៅរូបអម្រឹតសម្លាយ ។

៥១៥. សឹងជាងជាហង្សសព្វសាយ សត្វផងទាំងឡាយ ដោយពណ៌ទីទៃនានា ។

៥១៦. យល់ម្ករបវរថ្ងៃថ្វា ហែលលេងលីលា លលកណ្តាលជលធី ។

៥១៧. ភ្ញុកភ្នៅស្មើស្មាទាំងពីរ ស្រកាស្រកី រូបហាក់វិញ្ញាណរូបរស់ ។

៥១៨. វាត់វាយទឹកខ្វាយខ្ពង់ខ្ពស់ អស់អង្គស្រេចស្រស់ ប្រដាប់សឹងមាសច្រាសច្រាល។

៥១៩. រូបនាគលោលើកពពារ អរឯងបីត្រអាល ក៏ហែលលេងលើជលសា ។

៥២០. ឃ្មាតខ្មាញ់ហាក់ដេញមច្ឆា ត្រីផងនានា វេរានិងនាគនោះណា ។

៥២១. រូបរាជសីហៀវហោះ ប្រែប្រាណស្ទាត់ស្ទុះ ក៏ចាប់អម្រឹតយុងឃ្នង ។

៥២២. យន្តកេសររាជសីហ៍ផង ចរចេញលេងលង ក៏ហោះកណ្តាលនភី ។

៥២៣. ចុះចាប់ទងកែសរភ្ញី ចាប់បានឆាប់ឆី រូបហាក់រូបរស់វិស័យ ។

៥២៤. ប្រែប្រឹងបីសន្ធឹងវិលវៃ នេត្រនោះរំពៃ ក្រឡេកក្រលួងបីសម្ញឹង ។

៩២៥. យន្តមួយធ្វើជារូបហង្ស ឈរឈប់ប្រែប្រើង ក្រឡឹកក្រឡៀវនេត្រា ។

៩២៦. យន្តស្ទាន់ទួរយន្តលៀងភារ ពារយុទ្ធនិងគ្នា កណ្ដាលនៃអាកាសកង ។

៩២៧. យន្តហង្សរាជរូបឥតធ្លង ចរចេញលេងលង ក៏ហោះកណ្ដាលវេហាស៍។

៩២៨. វីយន្តគីលេនលីលា ទៀបនិងមនោរា ប្រយុទ្ធកណ្ដាលនភី ។

៩២៩. យន្តហង្សក៏សឹងពាំភ្ញី ទាំងទងវីកថ្មី គ្របកប្ដូទមសុវណ្ណា ។

៩៣០. យន្តគ្រុឌផៀងផាបនាគា នាគព័ន្ធហត្ថា សម្ដែងនូវឫទ្ធិបីពន្លឹក ។

៩៣១. រូបខ្លាចាប់អង្គអម្រឹគ ក្រាបក្រោមព្រៃព្រឹក្ស ក្រឡាស់ក្រឡាប់ហានក្រៃ ។

៩៣២. ហាក់ដូចរូបរស់វិស័យ សក្តិសមពេកក្រៃ ក៏ស្ទុះលោលោតវិលវៃ ។

៩៣៣. រូបគុជសារស្លឹមស្លៃ គោជ៍គោព្រេចព្រៃ ក៏ស្រប់ក្រោមម្លប់អគ្ធា ។

៩៣៤. រូបគោរូបគោមហិង្សា រូបហង្សនានា អនេកអនន្តណាស់នៃ ។

៩៣៥. រូបបក្សីផងក្រាសក្រៃ ទំដោយព្រឹក្សព្រៃ ប្រចឹកប្រចាប់ទងភ្ញី ។

៩៣៦. រូបខ្វះលោតលេងដោយដី ខ្វះលើកទងភ្ញី ក៏ទំលែងលើព្រឹក្សា ។

៩៣៧. រូបសេកនូវរូបសារិកា ទំទឹមខាងគ្នា ក៏ចឹកនៃបុប្ផផង ។

៩៣៨. រូបកិន្នរីសោតហោង យាងយាសផ្ទៀងផ្ទង ទាំងគូបក្សារេរាំ ។

៩៣៩. កែងកាងយាងយាសបីទន្ទាំ ចាឧបទលំនាំ ជជាយជជួរកែងករ ។

៩៤០. ធ្វើរូបនាងទេពអប្សរ ទ្រង់ពស្ត្រាពរ ករកាន់នូវភ្ញីទាំងទង ។

៩៤១. រេរាំទន់ភ្ទន់បីលំញ៉ង ស្រស់ស្រេចឥតធ្លង ស្រលូតស្រឡះឆោមឆាយ។

៩៤២. កាល្មោះព្រះកេតុមាលា ពិសេសសោភា ស្ដេចឲ្យប្រជាប់សព្វគ្រប់ ។

៩៤៣. ទើបស្ដេចឲ្យរៀបប្រដាប់ ប្រាប់ប្រើពលទ័ព ឲ្យរៀបនូវគ្រឿងគ្រប់ដៃ ។

" ចប់ "

៩៤៤. ល្បើកនេះបុរាណរាជយូរលង់ តែងតពីក្នុងនគរវត្ត លើកតាមប្រជាប់បុណ្យក្សត្រិយ៍
រាជ្យរដ្ឋព្រះកេតុមាលាថ្លៃ ។

៩៤៥. ស្ដេចមានបុណ្យថ្កើងប្រសើរខ្ពស់ ឋិតឋានយូរលង់ឧត្តមក្រៃ គ្មានគេនឹងមកប្រឡងជ័យ
ក្សត្រិយ៍ថ្លៃស្ដេចគង់សុខក្សេមក្សាន្ត ៕